ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២០

# របាយការណ៍ចុងក្រោយ

## វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

សហការជាមួយ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២០

# របាយការណ៍ចុងក្រោយ

## វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

## សហការជាមួយ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# មាតិកា


បុព្វកថា .......... III
អារម្ភកថា .......... IV
សមាសភាពគណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ .......... V
សេចក្តីសង្ខេប .......... 1
  ទិដ្ឋភាពទូទៅនៃវិធីសាស្រ្តអង្កេត .......... 1
  សូចនាករសង្ខេប .......... 3
អក្សរសរសេរកាត់ .......... 7
**ជំពូកទី១ ៖ វិសាលភាព ការគ្របដណ្តប់ និងការជ្រើសរើសសំណាកគំរូ .......... 8**
  គោលបំណង .......... 8
  វិធីសាស្រ្ត .......... 8
  វិសាលភាពនៃការអង្កេត .......... 9
  ទីតាំងភូមិសាស្រ្តគ្របដណ្តប់ .......... 9
  រយៈពេលនៃការអង្កេត និងកាលបរិច្ឆេទយោង .......... 10
  តារាងបញ្ជីសំណាកគំរូ .......... 10
  វិធីសាស្រ្តក្នុងការជ្រើសរើសសំណាកគំរូ .......... 11
  មេគុណ និងការប៉ាន់ស្មាន .......... 13
  វិធីសាស្រ្តសម្រាប់សហគ្រាសកសិកម្មខ្នាតធំ .......... 13
  នីតិវិធីអង្កេត .......... 13
  យន្តការជំនួយក្នុងការសម្ភាសន៍ .......... 14
  ប្រតិបត្តិការប្រមូលទិន្នន័យ .......... 14
  ការកែច្នៃទិន្នន័យ .......... 15
  បទដ្ឋាននៃការបោះពុម្ពផ្សាយ .......... 16
  ដែនកំណត់នៃការអង្កេតកសិកម្ម .......... 16
**ជំពូកទី២ ៖ លក្ខណៈនៃការកាន់កាប់កសិកម្ម .......... 17**
  ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ .......... 18
  ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ .......... 19
**ជំពូកទី ៣ ៖ ផលិតកម្មដំណាំ .......... 20**
  ដំណាំធញ្ញជាតិ និងធញ្ញជាតិយកគ្រាប់ .......... 21
  ដំណាំយកមើម .......... 22
  ដំណាំពពួកសណ្តែកយកគ្រាប់ .......... 23
  ដំណាំប្រភេទគ្រាប់យកប្រេង .......... 23
  រុក្ខជាតិជាគ្រឿងទេស គ្រឿងក្រអូប រុក្ខជាតិឱសថ .......... 23

ដំណាំឧស្សាហកម្ម ... 24
ដំណាំបន្លែ ... 24
ដំណាំហូបផ្លែ ... 25
ដំណាំស្វាយចន្ទី ... 27
ដំណាំយកប្រេង ... 28
ដំណាំគ្រឿងទេស និងគ្រឿងក្រអូប ... 28
ដំណាំកៅស៊ូ ... 28
ដំណាំមិនមែនអាហារ ... 28
ការប្រើប្រាស់ជី សារធាតុគីមី និងប្រព័ន្ធស្រោចស្រព ... 29
**ជំពូកទី៤ ៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ... 29**
បសុសត្វធំ ... 31
*គោ ... 31*
*ក្របី ... 32*
បសុសត្វតូច ... 34
បសុបក្សី ... 35
**ជំពូកទី៥ ៖ វារីវប្បកម្ម និងការនេសាទ ... 37**
ផលនេសាទ ... 37
វារីវប្បកម្ម ... 39
**ជំពូកទី៦ ៖ សកម្មភាពសេដ្ឋកិច្ចបន្ថែមនៅក្នុងគ្រួសារកសិកម្ម ... 40**
**ជំពូកទី៧ ៖ គ្រួសារកសិកម្ម និងស្ថានភាពប្រជាសាស្ត្រ ... 44**
**ជំពូកទី៨ ៖ កម្លាំងពលកម្មចូលរួមក្នុងសកម្មភាពកសិកម្ម ... 46**
**ជំពូកទី៩ ៖ ព័ត៌មានអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ... 47**
**ឧបសម្ព័ន្ធ១ ៖ តារាងទិន្នន័យសង្ខេប ... 59**
លក្ខណៈនៃការកាន់កាប់កសិកម្ម ... 60
ផ្ទៃដីកសិកម្ម និងផលិតកម្មដំណាំ ... 68
បសុសត្វ និងបសុបក្សី ... 159
វារីវប្បកម្ម និងការនេសាទ ... 183
សេដ្ឋកិច្ច ... 190
គ្រួសារកសិកម្ម និងប្រជាសាស្ត្រ ... 212
ពលកម្មក្នុងវិស័យកសិកម្ម ... 230
តារាងបែងចែកតាមប្រភេទនៃការកាន់កាប់កសិកម្ម ... 234
**ឧបសម្ព័ន្ធ២ ៖ កម្រងសំណួរអង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២០ ... 280**

# បុព្វកថា

នៅព្រះរាជាណាចក្រកម្ពុជា វិស័យកសិកម្មជាវិស័យដ៏សំខាន់មួយសម្រាប់ទ្រទ្រង់សេដ្ឋកិច្ចកម្ពុជា ដែលបានរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចមានប្រមាណ ២២,៦ ភាគរយ នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០២០។

ខ្ញុំសូមវាយតម្លៃខ្ពស់លើរបាយការណ៍លទ្ធផលចុងក្រោយ នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ដែលបានបង្ហាញទិន្នន័យស្ថិតិដែលមានសារប្រយោជន៍បំផុត អំពីការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងការនេសាទ ព្រមទាំងលក្ខខណ្ឌបច្ចេកទេសកសិកម្ម បរិស្ថាន សេដ្ឋកិច្ច និងសង្គមគ្រួសារកសិកម្មកម្ពុជា។ សូចនាករសំខាន់ៗនៃអង្កេតកសិកម្មដែលបានបង្ហាញក្នុងរបាយការណ៍នេះ នឹងជួយគាំទ្រដល់ការវាយតម្លៃពីវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងគោលនយោបាយកាត់បន្ថយភាពក្រីក្រ គណនាកំណើនសេដ្ឋកិច្ចជាតិ (ចំណូលជាតិ) និងកម្មវិធីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងទៀត។ ទិន្នន័យអង្កេតកសិកម្មកម្ពុជានឹងជួយឆ្លុះបញ្ចាំងនូវវឌ្ឍនភាពឆ្ពោះទៅសម្រេច គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ សម្រាប់វិស័យកសិកម្មដោយផ្ដោតលើ៖

-គោលដៅទី១ ៖ ការបញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង។

-គោលដៅទី២ ៖ ការបញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀងធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភនិងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព។

-គោលដៅទី៥ ៖ សម្រេចឱ្យបានសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារគ្រប់រូប។

-គោលដៅទី៦ ៖ ធានាឱ្យមានទឹកស្អាតនិងអនាម័យ និងការគ្រប់គ្រងទឹក និងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប។

ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) មូលនិធិមីលីនដាប៊ៀលហ្គេត (The Bill and Melinda Gates Foundation) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍ (USAID) និងដៃគូអភិវឌ្ឍ នៃកម្មវិធីផ្ដួចផ្ដើមអភិវឌ្ឍទិន្នន័យកសិកម្ម ៥០ x ២០៣០ (The 50 x 2030 Initiative to close the Agriculture Data Gap) ដែលបានគាំទ្រផ្នែកបច្ចេកទេស និងថវិកា សម្រាប់ការអនុវត្តការងារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ឱ្យសម្រេចបានជោគជ័យប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលាសម្រាប់បំពេញតម្រូវការប្រើប្រាស់ទិន្នន័យទោះ បីជាស្ថិតនៅក្នុងកាលទេសដែលប្រឈមនឹងបរិបទ នៃជំងឺកូវីដ១៩ រាតត្បាតសកលក៏ដោយ។

ជាចុងក្រោយ ខ្ញុំសូមកោតសរសើរដល់ ឯកឧត្តម **រិន ទីរៈ** រដ្ឋលេខាធិការប្រចាំការ ឯកឧត្តម **ហោ ដារិទ្ធ** រដ្ឋលេខាធិការ ក្រសួងផែនការ លោកជំទាវ **ហាង លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងមន្ត្រីទាំងអស់ដែលបានខិតខំប្រឹងប្រែងអនុវត្តការងារអង្កេតកសិកម្មកម្ពុជា និងវិភាគរបាយការណ៍លទ្ធផលនេះ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ សូមបង្ហាញអំពីរបាយការណ៍ការវិភាគលទ្ធផលចុងក្រោយនៃទិន្នន័យអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ (CAS2020) ដែលបានពីការធ្វើសម្ភសន៍លើសំណាកគំរូប្រមាណជាង ១៥.០០០ គ្រួសារកសិកម្មនៅរាជធានីខេត្តទាំង២៥ ។ ការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ត្រូវបានអនុវត្តអនុលោមតាមកិច្ចព្រមព្រៀងរវាងក្រសួងផែនការ និងអង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) ប្រចាំកម្ពុជា នាថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨ ។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ត្រូវបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដោយសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង អង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ ដែលមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុបដិភាគ ពីរាជរដ្ឋាភិបាលកម្ពុជា អង្គការ (FAO) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍ (USAID) និងដៃគូអភិវឌ្ឍនៃកម្មវិធីផ្តួចផ្តើមអភិវឌ្ឍទិន្នន័យកសិកម្ម ៥០ x ២០៣០ (The 50 x 2030 Initiative to close the Agriculture Data Gap)។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ បានប្រើប្រាស់បច្ចេកទេសសម្ភាសន៍ដោយប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រខ្នាតតូច (Tablet-CAPI) ដែលប្រើកម្មវិធីអង្កេតសូឡូស្យុង (Survey Solutions) សម្រាប់សម្ភាសន៍កត់ត្រា និងគ្រប់គ្រងទិន្នន័យអង្កេតកសិកម្មកម្ពុជា។ ទិន្នន័យដែលប្រមូលបានពីគ្រួសារកាន់កាប់កសិកម្ម ក៏ដូចជា ផ្នែកមិនមែនគ្រួសារ និងសហគ្រាសកសិកម្មខ្នាតធំ ត្រូវបានបញ្ចូលក្នុងរបាយការណ៍វិភាគទិន្នន័យចុងក្រោយផងដែរ។ របាយការណ៍អង្កេតនេះ បានបង្ហាញទិន្នន័យស្តីពីផលិតកម្មដំណាំ ការចិញ្ចឹមសត្វ វារីវប្បកម្ម និងការនេសាទ កម្លាំងពលកម្មក្នុងវិស័យកសិកម្ម សម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិកសិកម្មឱ្យបានទៀងទាត់ ដើម្បីបំពេញតម្រូវការរបស់អ្នកធ្វើគោលនយោបាយ និងគោលដៅអភិវឌ្ឍន៍កសិកម្ម និងបរិស្ថាន។

នាងខ្ញុំសូមថ្លែងអំណរគុណជាអនេកដល់ក្រសួង ស្ថាប័ន និងអង្គការនានា សមាជិក សមាជិកានៃគណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជា និងក្រុមការងារស្នូលបច្ចេកទេសអង្កេតកសិកម្មកម្ពុជា ជំនាញការពីអង្គការ (FAO) និងមន្ត្រីទាំងអស់ដែលបានចូលរួមអនុវត្តការងារប្រមូល ចងក្រង និងវិភាគទិន្នន័យស្ថិតិនៃរបាយការណ៍លទ្ធផលចុងក្រោយនៃអង្កេតកសិកម្មកម្ពុជា ឱ្យសម្រេចបានជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

នាងខ្ញុំយល់ថា របាយការណ៍នេះនឹងផ្តល់ធាតុចូលដ៏សំខាន់ក្នុងការរៀបចំកម្មវិធីគោលនយោបាយអភិវឌ្ឍន៍កសិកម្មប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាព។ របាយការណ៍នេះ ត្រូវបានបើកចំហសម្រាប់ការពិភាក្សា ព្រមទាំងទទួលនូវរាល់មតិយោបល់ ឬអនុសាសន៍សម្រាប់ការកែលម្អអភិវឌ្ឍន៍របាយការណ៍លទ្ធផលឱ្យកាន់តែល្អថែមទៀតនាពេលអនាគត។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក**
**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហង់ លីណា**

# សមាសភាពគណៈកម្មការបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០

| **នាម និងគោត្តនាម** | **ស្ថាប័ន** | **តួនាទី** |
|---|---|---|
| ឯកឧត្តម ហោ ដារិទ្ធ | រដ្ឋលេខាធិការ ក្រសួងផែនការ | **ប្រធាន** |
| ឯកឧត្តម ទុយ ចំរើន | រដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ឯកឧត្តម ខៀវ សារី | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| ឯកឧត្តម សេង សឿន | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | អនុប្រធាន |
| លោកជំទាវ ហង់ លីណា | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយក វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| លោក ម៉ក់ មុនី | ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| លោកស្រី មាស សុទ្ធារី | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ឯកឧត្តម ចាន់ យុត្ថា | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| លោក ឃ្លោក សំអាង | ប្រធាននាយកដ្ឋាន ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ឯកឧត្តម ឆាយ សត្យា | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិត នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម ឃិន សុង | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម ឃិន សុវលក្ខណ៍ | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម លន់ គឹមលាង | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម ចាន់ សំអាត | ប្រធាននាយកដ្ឋាន វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| លោក ជូរ ជេតទីវន្ត | អគ្គនាយករង នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| លោក ហ៊ុន សាង | ប្រធាននាយកដ្ឋាន នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| ឯកឧត្តម ឈួន សំរិទ្ធ | អគ្គនាយក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| លោក សុខ ខន | ប្រធាននាយកដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ឯកឧត្តម ស៊ីសុវត្ថិ ដួងច័ន្ទទោ | ប្រធានអគ្គលេខាធិការដ្ឋានគ.ជ.ក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| លោកស្រី ហាក់ គឹមឡុង | មន្ត្រីស្រាវជ្រាវ អគ្គលេខាធិការដ្ឋានគ.ជ.ក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកា |
| កញ្ញា ឯម ភក្តី | ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានគ.ជ.ក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកា |
| លោកស្រី ហេង លីនដា | អនុប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានគ.ជ.ក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកា |
| លោកស្រី លឹម កិត្យា | ប្រធាននាយដ្ឋាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| លោក យីត ស៊ុនណារោឧត្តម | អនុប្រធាននាយកដ្ឋាន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | |
|---|---|---|
| ឯកឧត្តម ពេជ ពោធី | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម សាំង ឡុងឌី | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម ជា ចាន់តុលា | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| ឯកឧត្តម គង់ សេង | អគ្គនាយករង វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | សមាជិក |
| លោក ទូ សុធូ | ប្រធាននាយកដ្ឋានសេដ្ឋកិច្ច វិនិយោគ និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| លោក ប៉ិច សុខពោ | អនុប្រធាននាយកដ្ឋាន ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ឯកឧត្តម អ៊ុយ យាង | អនុប្រធាននាយកដ្ឋាន និងជាទីប្រឹក្សាក្រសួងព័ត៌មាន | សមាជិក |
| លោក សាន ចំរើន | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌនិងខេត្តនៃ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| លោកបណ្ឌិត លឿង កេសរោ | អគ្គនាយករង ក្រសួងបរិស្ថាន | សមាជិក |
| លោក ធឹង សុជាត | អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| លោក លុច្ស រចនា | ជំនួយការឯកឧត្តមរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| លោក ប៊ុត សាខន | អនុប្រធាននាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| លោក សូ តូនែរ | អនុប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ច វិទ្យាស្ថានជាតិស្ថិតិ | សមាជិក |
| ឯកឧត្តម ណោ វ៉ាន់ឌី | ប្រធាននាយកដ្ឋានស្ថិតិសេដ្ឋកិច្ចនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | លេខាធិការ |

# សេចក្ដីសង្ខេប

## ទិដ្ឋភាពទូទៅនៃវិធីសាស្រ្តអង្កេត

ការអង្កេតកសិកម្មកម្ពុជា (CAS) នៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឡើងក្នុងឆ្នាំ២០២០-២០២១ គឺជាកិច្ចការស្ថិតិទូលំទូលាយមួយសម្រាប់ការប្រមូល និងចងក្រងព័ត៌មានស្ដីពីការដាំដំណាំ ការចិញ្ចឹមបសុសត្វនិងបសុបក្សី ព្រមទាំងការធ្វើវារីវប្បកម្ម និងការនេសាទ។ ទិន្នន័យដែលប្រមូលបាន និងដែលបង្កើតបានពីការអង្កេតនេះ នឹងមានប្រយោជន៍សម្រាប់ការរៀបចំផែនការ គោលនយោបាយ និងកម្មវិធីសម្រាប់ការអភិវឌ្ឍ និងការកែលម្អវិស័យកសិកម្ម និងនេសាទ នៅប្រទេសកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ (MOP) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MAFF) គឺជាស្ថាប័នរបស់រដ្ឋាភិបាលដែលមានតួនាទីទទួលខុសត្រូវ និងបានទទួលការអនុញ្ញាតឱ្យធ្វើការអង្កេតនេះ។ វិទ្យាស្ថានជាតិស្ថិតិមានតួនាទីនិងភារៈកិច្ចធ្វើជំរឿន និងអង្កេត ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ចម្បងនូវទិន្នន័យ ដែលបានពីការអង្កេតនេះ។

គោលបំណងសំខាន់នៃការអង្កេតកសិកម្មប្រចាំឆ្នាំគឺ ផ្ដល់បច្ចុប្បន្នភាពទិន្នន័យស្ដីពីសកម្មភាពកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់អ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយយកទៅប្រើប្រាស់។ វិធីសាស្រ្តជ្រើសរើសសំណាកគំរូ សម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ពឹងផ្អែកទាំងស្រុងលើការជ្រើសរើសសំណាកគំរូពីការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩។ ដោយសារតែឧបសគ្គបណ្ដាលពីរោគរាតត្បាតកំពុងកើតឡើង សុវត្ថិភាពនិងបញ្ហាថវិកាសកម្មភាពចុះបញ្ជីគ្រួសារមិនអាចធ្វើទៅបានឡើយ។ ដូច្នេះ សំណាកគំរូអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ត្រូវបានយកមកប្រើប្រាស់ឡើងវិញក្នុងវិធីសាស្រ្តសំណាកគំរូដដែល (Panel Approach) សម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០។ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ បានប្រើវិធីសាស្រ្តស្ថិតិដើម្បីជ្រើសយកសំណាកគំរូពីមណ្ឌលជំរឿន (EA) នៅ ទូទាំងប្រទេសកម្ពុជា ពីបញ្ជីឈ្មោះមណ្ឌលជំរឿន នៃជំរឿនកសិកម្មឆ្នាំ២០១៣។ គ្រួសារទាំងអស់នៅក្នុង EA ទាំងនេះត្រូវបានពិនិត្យដោយផ្អែកលើសកម្មភាពកសិកម្មទាំងឡាយដែលមាន។ ដោយប្រើព័ត៌មាននេះជាគោល ការអង្កេតនេះបានបែងចែកគ្រួសារកាន់កាប់កសិកម្មទៅជាក្រុម និងជ្រើសយកជាសំណាកសម្រាប់ការប្រមូលទិន្នន័យបន្ថែម។ ដោយសារកិច្ចប្រឹងប្រែងនេះផ្ដោតជាសំខាន់លើការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ ដូច្នេះការអង្កេតនេះបានធ្វើសម្ភាសន៍ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ក្នុងចំនួនតិចតួចប៉ុណ្ណោះ។ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ សំដៅទៅលើសហគ្រាសដែលដំណើរការជាលក្ខណៈក្រុមហ៊ុន សាជីវកម្ម សហគមន៍ រដ្ឋាភិបាល ឬគ្រឹះស្ថានឯកជន។ កិច្ចប្រឹងប្រែងដាច់ដោយឡែកដែលផ្ដោតលើការប្រមូលទិន្នន័យអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ បានធ្វើឡើងជាក្រោយ ដោយផ្ដោតលើការចុះបញ្ជីប្រតិបត្តិការសហគ្រាសកសិកម្មខ្នាតធំ ដែលបានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) និងការិយាល័យផ្សេងទៀតនៃរដ្ឋាភិបាលដែលមានព័ត៌មានអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ។

ការប្រមូលទិន្នន័យសម្រាប់ការអង្កេតនេះ ត្រូវបានធ្វើឡើងដោយសម្ភាសន៍ទុលមុខផ្ទាល់ ដោយមានជំនួយពីកុំព្យូទ័រ (CAPI) ។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះ ត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធី Survey Solutions របស់ធនាគារពិភពលោក។ ការប្រើប្រាស់ CAPI សម្រាប់ការប្រមូលទិន្នន័យបានផ្ដល់អត្ថប្រយោជន៍ជាច្រើន រួមទាំង កាត់បន្ថយការចំណាយលើការបោះពុម្ពតារាងបញ្ជីសំណួរ ការវាយបញ្ចូលទិន្នន័យ និងអនុញ្ញាតឱ្យត្រួតពិនិត្យគុណភាព និងវិភាគទិន្នន័យបានឆាប់រហ័ស និងកាន់តែប្រសើរ។

ដោយប្រើសំណាកគ្រួសារគំរូពី អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ពិនិត្យមើលសំណាកគំរូនៅទូទាំងប្រទេស លើកលែងតែខណ្ឌចំនួនប្រាំមួយក្នុងរាជធានីភ្នំពេញ ក្រុងមួយក្នុងខេត្តព្រះសីហនុ និងក្រុងមួយក្នុងខេត្តសៀមរាប ដែលត្រូវបានចាត់ជាទីប្រជុំជន។ សម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ មានសំណាកគំរូ

សរុប ១៥.៩៨២ គ្រួសារ ដែលបានរាយការណ៍ពីសកម្មភាពកសិកម្មតាំងពីមុនមក នៅក្នុងអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩ ។ ទិន្នន័យត្រូវបានប្រមូលយកពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំចំនួន១៩៧ ផងដែរ។

ព័ត៌មានលម្អិតបន្ថែមអំពីនីតិវិធីជ្រើសយកសំណាក វិធីសាស្ត្រអង្កេត និងប្រតិបត្តិការនៅតាមភូមិសាស្ត្រសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ និង អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ មានបង្ហាញនៅក្នុងជំពូកទី ១ – វិសាលភាពការគ្របដណ្តប់ និងការជ្រើសរើសសំណាកគំរូ។ ការសម្ភាសផ្នែកកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ បានធ្វើឡើងចាប់ពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២១ ចំណែកការសម្ភាសការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ បានចាប់ផ្តើមពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២១។ អំឡុងពេលយោងសម្រាប់ការអង្កេតនេះ គឺ ១២ខែ គិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០។ មន្ត្រីសម្ភាសន៍សរុបចំនួន ៣៦៨ នាក់ បានចូលរួមក្នុងការប្រមូលទិន្នន័យនេះ ដែលជាមន្ត្រីនៅវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្នាក់ខេត្ត និងថ្នាក់ ស្រុក។ មានអ្នកគ្រប់គ្រងទិន្នន័យចំនួន ៤៦ នាក់ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ ចំណែកអ្នកគ្រប់គ្រងតាមភូមិសាស្ត្រ ចំនួន ៤៦ នាក់ ទទួលខុសត្រូវជួយអ្នកប្រមូលទិន្នន័យក្នុងការដោះស្រាយបញ្ហានៅតាមភូមិសាស្ត្រ លើកទឹកចិត្តឱ្យមានទំនាក់ទំនងល្អនៅតាមភូមិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការពីការកាន់កាប់កសិកម្ម ជាលក្ខណៈគ្រួសារនៅក្នុងការអង្កេតនេះ។

ការអង្កេតកសិកម្ម បានប្រើប្រាស់និយមន័យ "ការកាន់កាប់កសិកម្ម" ដែលកំណត់ដោយកម្មវិធីពិភពលោកសម្រាប់ជំរឿនកសិកម្មឆ្នាំ២០២០ (WCA 2020) និងយុទ្ធសាស្ត្រសកលដើម្បីកែលម្អស្ថិតិកសិកម្ម និងជនបទ (GSARS) ។ ការកាន់កាប់កសិកម្មត្រូវបានកំណត់ថាជា អង្គភាពសេដ្ឋកិច្ចនៃផលិតកម្មកសិកម្មក្រោមការគ្រប់គ្រងតែមួយ ដែលរួមមាន បសុសត្វទាំងអស់ដែលបានរក្សាទុក និងដីទាំងអស់ដែលត្រូវបានប្រើប្រាស់ទាំងស្រុង ឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពីរូបភាពនៃកម្មសិទ្ធិ ទម្រង់នៃការកាន់កាប់ ឬទំហំឡើយ។ ការគ្រប់គ្រងណាមួយ អាចត្រូវបានអនុវត្តដោយបុគ្គល ឬគ្រួសារ ដោយបុគ្គលពីរនាក់ ច្រើននាក់ ឬច្រើនគ្រួសាររួមគ្នា ដោយត្រកូល ឬកុលសម្ព័ន្ធ ឬដោយនីតិបុគ្គល ដូចជា សាជីវកម្ម សហគមន៍ ឬស្ថាប័នរដ្ឋាភិបាល។ ដីនៅក្រោមការកាន់កាប់កសិកម្ម អាចមានក្បាលដីមួយ ឬច្រើន ដែលមានទីតាំងនៅតំបន់ដាច់ដោយឡែកមួយ ឬច្រើន ឬនៅក្នុងភូមិសាស្ត្រ ឬរដ្ឋបាលដែនដីមួយ ឬច្រើន ដោយផ្តល់ក្បាលដី ដែលមានមធ្យោបាយផលិតដូចគ្នា ដូចជា ពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬកម្លាំងអូសទាញ។ វិសាលភាពនៃសកម្មភាពកសិកម្ម មានដូចជាការដាំដំណាំដែលមានអាយុកាលច្រើនឆ្នាំ ឬពុំមានអាយុកាលច្រើនឆ្នាំ ការបង្កាត់ពូជរុក្ខជាតិ ផលិតកម្មសត្វ ឬការធ្វើកសិកម្មចម្រុះ។ សកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មផ្សេងទៀត ដូចជា ការនេសាទ ព្រៃឈើ និងវារីវប្បកម្ម សម្រាប់ជាអាទិភាពចម្បងសម្រាប់វិស័យកសិកម្ម។

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ក៏ដូចជា ការអង្កេតសំណាកគំរូទាំងអស់ សុទ្ធតែមានដែនកំណត់ លើទិន្នន័យដែលបានផលិត និងការបកស្រាយ ឬប្រៀបធៀបទៅនឹងប្រភពទិន្នន័យជំនួស។ អ្នកអានអាចយោងទៅផ្នែកដែនកំណត់នៃការអង្កេតកសិកម្មពេញលេញនៅក្នុងជំពូកទី១។ ជាទូទៅ អ្នកអានគួរតែដឹងពីដែនកំណត់នៃទិន្នន័យអង្កេតដែលរាយការណ៍ដោយខ្លួនឯង កម្រិតកំណត់លើវិសាលភាពគ្របដណ្តប់នៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ក្នុងប្រទេសកម្ពុជា ឈ្មោះមណ្ឌលជំរឿនដែលបានកំណត់សម្រាប់ប្រើក្នុងការអង្កេតនេះ និងដែនកំណត់នៃកម្រងសំណួរសម្រាប់ការអង្កេត និងនីតិវិធីសម្ភាសន៍ផងដែរ។

## សូចនាករសង្ខេប

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប្រើប្រាស់កម្រងសំណួរចម្បងមួយនៃការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ ។ កម្រងសំណួរដូចគ្នានេះក៏ត្រូវបានប្រើដើម្បីប្រមូលទិន្នន័យពីការកាន់កាប់កសិកម្មមិនមានលក្ខណៈជាគ្រួសារ ឬ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំផងដែរ។ ទម្រង់នេះមាន១០ផ្នែកសំខាន់ៗ៖

១. ការកំណត់អត្តសញ្ញាណរបស់អ្នកឆ្លើយ និងការយល់ព្រមជាមុន

២. លក្ខណៈនៃការកាន់កាប់

៣. សកម្មភាពផលិតកម្មដំណាំ

រាប់បញ្ចូលទាំង ផ្ទៃដីដាំ និងប្រមូលផល បរិមាណផលិត ភាគចំណែកផលិតផលដែលបានលក់ ឬសម្រាប់ប្រើក្នុងគ្រួសារ ការប្រើប្រាស់ដី ប្រព័ន្ធស្រោចស្រព ថ្នាំសម្លាប់សត្វល្អិត ការប្រើប្រាស់គ្រាប់ពូជដែលគ្មានការបញ្ជាក់ ឬកែលម្អ ។ល។

៤. សកម្មភាពបសុសត្វ បសុបក្សី និងសត្វល្អិត

រាប់បញ្ចូលទាំង ចំនួនកាន់កាប់ដែលមានចិញ្ចឹមសត្វក្នុងអំឡុងពេល ១២ ខែកន្លងមក ចំនួនសត្វដែលមានក្រោមការកាន់កាប់ សកម្មភាពសត្តឃាដ ជាដើម។

៥. សកម្មភាពវារីវប្បកម្ម និងការនេសាទ

រួមទាំងចំនួនកាន់កាប់ដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ ប្រភេទសត្វក្នុងវារីវប្បកម្ម បរិមាណពីសកម្មភាពនេសាទជាដើម។

៦. សេដ្ឋកិច្ច

រួមទាំងសកម្មភាពរកប្រាក់ចំណូលបន្ថែម ផលប៉ះពាល់ដែលអ្នកកាន់កាប់បានជួបប្រទះ។ល។

៧. សមាជិកគ្រួសារ

រួមទាំងទិន្នន័យប្រជាសាស្ត្រ នៃសមាជិកគ្រួសារ កម្រិតនៃការសិក្សាជាដើម។

៨. កម្រិតយោងអំពីអសន្តិសុខស្បៀងដែលគ្រួសារធ្លាប់ជួបប្រទះ

ការវាយតម្លៃកម្រិតអសន្តិសុខស្បៀងសម្រាប់សមាជិកគ្រួសារដែលធ្លាប់ជួបប្រទះក្នុងអំឡុងពេល១២ខែកន្លងមក។

៩. ពលកម្មដែលមានប្រើប្រាស់នៅក្នុងការកាន់កាប់កសិកម្ម

រួមទាំងកម្លាំងពលកម្មក្នុងគ្រួសារ និងបានមកពីក្រៅគ្រួសារ និងកម្មករម្តងម្កាល ចែកដាច់គ្នាតាមភេទ ។ល។

១០. បញ្ចប់ការអង្កេត

គន្លឹះទិន្នន័យសំខាន់ៗ ទាញចេញពីការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ បង្ហាញក្នុងតារាងខាងក្រោមសម្រាប់ទិន្នន័យកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់រួមមាន៖ តំបន់វាលទំនាប តំបន់បឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំ និងខ្ពង់រាបផងដែរ។

| សូចនាករសង្ខេប៖ ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ | | | | | |
|---|---|---|---|---|---|
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារកសិកម្ម (គិតជាពាន់) | 2,038 | 871 | 723 | 141 | 304 |
| ភាគរយនៃគ្រួសារកសិកម្មផលិតកម្មកសិកម្មសម្រាប់៖ | | | | | |
| ចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ | 61% | 62% | 54% | 85% | 64% |
| ចម្បងសម្រាប់លក់ | 39% | 38% | 46% | 15% | 36% |
| ភាគរយនៃគ្រួសារមានតែដីបរិវេណលំនៅដ្ឋាន | 14% | 14% | 14% | 19% | 10% |
| ចំនួនក្បាលដីជាមធ្យមនៃគ្រួសារដែលបានរាយការណ៍មានក្បាលដី | 1.8 | 1.8 | 1.8 | 2.1 | 1.8 |
| | | | | | |
| **ផលិតកម្មដំណាំតាមសកម្មភាព** | | | | | |
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារដែលបានដាំដំណាំ (គិតជាពាន់) | 1,920 | 821 | 681 | 130 | 289 |
| ភាគរយនៃគ្រួសារបានដាំដំណាំ | 94% | 94% | 94% | 92% | 95% |
| សម្រាប់ដំណាំដែលមានដាំភាគច្រើនជាចំនួនគ្រួសារបានរាយការណ៍ | ១. ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ដូង | ១. ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ដូង | ១. ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ដូង | ១. ស្រូវធម្មតា<br>២. ដូង<br>៣. ស្វាយ<br>៤. ចេក | ១. ស្រូវធម្មតា<br>២. ស្វាយ<br>៣. ចេក<br>៤. ស្វាយចន្ទី |
| | | | | | |
| **ការចិញ្ចឹមបសុសត្វបសុបក្សី និង/ឬសត្វល្អិត** | | | | | |
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារមានការចិញ្ចឹមបសុសត្វបសុបក្សី និង/ឬសត្វល្អិតនៅអំឡុងពេលណាមួយក្នុងឆ្នាំយោង (គិតជាពាន់) | 1,670 | 696 | 591 | 130 | 253 |
| ភាគរយនៃគ្រួសារមានការចិញ្ចឹមបសុសត្វ បសុបក្សី និង/ឬសត្វល្អិតនៅអំឡុងពេលណាមួយក្នុងឆ្នាំយោង | 82% | 80% | 82% | 92% | 83% |

| | | | | | |
|---|---|---|---|---|---|
| ចំនួនគ្រួសារមានការចិញ្ចឹមសត្វ គោ នៅអំឡុងពេលណាមួយក្នុងឆ្នាំយោង (គិតជាពាន់) | 752 | 328 | 235 | 62 | 127 |
| ចំនួនគោជាមធ្យមដែលគ្រួសារមានចិញ្ចឹម | 4.4 | 3.9 | 4.5 | 3.1 | 6.0 |
| ចំនួនគ្រួសារមានការចិញ្ចឹម បសុបក្សី នៅអំឡុងពេលណាមួយក្នុងឆ្នាំយោង (គិតជាពាន់) | 1,897 | 784 | 671 | 174 | 268 |
| ចំនួនបសុបក្សីជាមធ្យមដែលគ្រួសារមានចិញ្ចឹម | 33.6 | 33.7 | 34.9 | 39.4 | 25.8 |
| **សកម្មភាពវារីវប្បកម្ម និងនេសាទ** | | | | | |
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ចំនួនគ្រួសារមានធ្វើវារីវប្បកម្ម (គិតជាពាន់) | 125 | 82 | 29 | 7 | 7 |
| ភាគរយនៃគ្រួសារធ្វើវារីវប្បកម្ម | 6% | 9% | 4% | 5% | 2% |
| ចំនួនគ្រួសារនេសាទ (គិតជាពាន់) | 554 | 156 | 251 | 48 | 99 |
| ភាគរយនៃគ្រួសារធ្វើការនេសាទ | 27% | 18% | 35% | 34% | 33% |
| **សកម្មភាពសេដ្ឋកិច្ច** | | | | | |
| | **ប្រទេសកម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំ និងខ្ពង់រាប** |
| ភាគរយនៃគ្រួសារកសិកម្មដែលមានចំណូលទាំងស្រុងបានមកពីចំណូលកសិកម្ម | 4.1% | 3.2% | 5.3% | 5.6% | 3.5% |
| **ការរួមចំណែកពីចំណូលកសិកម្មទៅនឹងចំណូលសរុបនៃគ្រួសារប្រៀបធៀបទៅឆ្នាំមុន** | | | | | |
| ភាគរយនៃគ្រួសាររាយការណ៍មានចំណូលទាបជាង | 34% | 33% | 34% | 41% | 31% |
| ភាគរយនៃគ្រួសាររាយការណ៍មានចំណូលប្រហាក់ប្រហែលគ្នា | 56% | 56% | 57% | 44% | 60% |
| ភាគរយនៃគ្រួសាររាយការណ៍មានចំណូលខ្ពស់ជាង | 11% | 11% | 9% | 14% | 10% |

របាយការណ៍វិស័យកសិកម្មនេះបង្ហាញពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារសរុបចំនួន ២.០៣៨.០០០ ដោយមានការប៉ាន់ប្រមាណថា ៩៧% នៃចំនួនកាន់កាប់ជាលក្ខណៈគ្រួសារទាំងអស់ក្នុងប្រទេសកម្ពុជា បានពាក់ព័ន្ធក្នុងផលិតកម្មកសិកម្ម។

ផ្អែកតាមជំរឿនទូទៅប្រជាជន នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ នៅកម្ពុជាមានផ្ទះចំនួន ៣.៥៥៣.០២១ ខ្នង ។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ រាយការណ៍អំពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារប្រមាណ ២.០៣៨.០០០ គ្រួសារ ប្រមាណ ១៤% នៃគ្រួសារកសិកម្មបានរាយការណ៍ពីសកម្មភាពកសិកម្មនៅលើដីបរិវេណលំនៅស្ថានរបស់ខ្លួនប៉ុណ្ណោះ ។ អត្រានេះកើនឡើងបន្តិច ធៀបនឹងអត្រាប៉ាន់ប្រមាណ ១២% នៃគ្រួសារទាំងអស់ដែលរាយការណ៍ពីសកម្មភាពកសិកម្មតែលើដីបរិវេណលំនៅស្ថានរបស់ខ្លួន កាលក្នុងអំឡុងជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ ។ យោងតាមអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ គ្រួសារកសិកម្មនីមួយៗ កាន់កាប់ជាមធ្យមប្រមាណ១,៨ ក្បាលដី ចំណែកជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ បានប៉ាន់ប្រមាណថា អំពីចំនួននេះជាមធ្យមដល់ ២,៥ ក្បាលដី។

**៩៤% នៃគ្រួសារកសិកម្មទាំងអស់នៅកម្ពុជា បានរាយការណ៍អំពីសកម្មភាពដាំដំណាំ ដោយមានតែ ៨២% នៃគ្រួសារកសិកម្មទាំងអស់ប៉ុណ្ណោះ ដែលបានរាយការណ៍ពីការចិញ្ចឹមបសុសត្វ បសុបក្សី ឬសត្វល្អិត។**

ផ្អែកតាមអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ មានតែប្រមាណ ៩៤% នៃគ្រួសារកសិកម្មទាំងអស់ប៉ុណ្ណោះ ដែលបានរាយការណ៍ពីសកម្មភាពដាំដំណាំ។ តួលេខនេះកើនឡើងពី ៨៨% ដែលជារបាយការណ៍នៅក្នុងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ។ ខណៈដែលការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ បានប៉ាន់ប្រមាណថា ៨២% នៃគ្រួសារកសិកម្មទាំងអស់បានរាយការណ៍ពីការចិញ្ចឹមបសុសត្វ បសុបក្សី ឬសត្វល្អិត ការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ បានប៉ាន់ប្រមាណថា មានតែ ៧៥,៣% ប៉ុណ្ណោះដែលមានការចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី។

**ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប៉ាន់ប្រមាណថា ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារចំនួន ៥៥៤.០០០ បានធ្វើសកម្មភាពនេសាទ ក្នុងនោះ ៣៩% នៃការកាន់កាប់ទាំងនេះ បានរាយការណ៍ថា ផលចាប់របស់ពួកគាត់ទាបជាងឆ្នាំមុន។**

នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ មាន៥៥៤.០០០ គ្រួសារកសិកម្ម ដែលត្រូវបានប៉ាន់ស្មានថា បានធ្វើនេសាទ ដែលតួលេខនេះបានកើនឡើងធៀបនឹងចំនួន ២៣៤.០០០ គ្រួសារដែលបានប៉ាន់ប្រមាណក្នុងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩។ នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ គ្រួសារកសិកម្មបានប្រាប់ពីផលនេសាទរបស់ខ្លួន ក្នុងអំឡុងពេលយោងនៃការស្ទង់មតិនេះ ធៀបនឹងផលចាប់ក្នុងអំឡុងឆ្នាំមុន។ ក្នុងចំណោម ៥៤២.០០០ គ្រួសារ ដែលរាយការណ៍ថាបាននេសាទត្រី មានតែ ៣៩% ដែលរាយការណ៍ថាផលនេសាទរបស់ខ្លួនទាបជាងឆ្នាំមុន ៤៧% ថាផលនេសាទរបស់ខ្លួន ប្រហែលនឹងឆ្នាំមុន និង ១៤% ពោលថាផលនេសាទរបស់ខ្លួនបានច្រើនជាងឆ្នាំមុន។

**ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប៉ាន់ប្រមាណថា គ្រួសារកសិកម្ម ៣៤% រាយការណ៍ថាប្រាក់ចំណូលពីកសិកម្មមានទាបជាងឆ្នាំមុន។**

ការអង្កេតកសិកម្មបានសួរសំណួរផ្នែកសេដ្ឋកិច្ចជាច្រើន គ្រួសារកសិកម្មត្រូវបានស្នើឱ្យប៉ាន់ស្មានចំណែកនៃប្រាក់ចំណូលសរុបប្រចាំគ្រួសារ ដែលត្រូវបានគណនាជាប្រាក់ចំណូលពីកសិកម្មរបស់ខ្លួន។ ប្រមាណ ៣១% នៃគ្រួសារកសិកម្មបានរាយការណ៍ថា ប្រហែលពាក់កណ្ដាល (៤០% ទៅ ៥៩%) នៃប្រាក់ចំណូលសរុបប្រចាំគ្រួសាររបស់ខ្លួន បានមកពីកសិកម្ម ១៦% បានរាយការណ៍ថា ភាគច្រើនឬស្ទើរទាំងអស់ (៦០% ទៅ ៩៩%) នៃប្រាក់ចំណូលសរុបប្រចាំគ្រួសាររបស់ខ្លួន បានមកពីកសិកម្ម ហើយ ៤% បានរាយការណ៍ថា ប្រាក់ចំណូលសរុបទាំងអស់ប្រចាំគ្រួសាររបស់ខ្លួន បានមកពីកសិកម្ម។ លើសពីនេះ គ្រួសារទាំងនោះត្រូវបានស្នើឱ្យបង្ហាញប្រាក់ចំណូលពីកសិកម្មរបស់ខ្លួនក្នុងអំឡុងពេលយោង ធៀបនឹងប្រាក់ចំណូលពីកសិកម្មក្នុងអំឡុងឆ្នាំមុន។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប៉ាន់ប្រមាណថា ៣៤% នៃគ្រួសារកសិកម្មបានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មរបស់ខ្លួន មានទាបជាងឆ្នាំមុន ៥៦% បានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្ម ប្រហែលនឹងឆ្នាំមុន ហើយ ១១% បានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មមានច្រើនជាងឆ្នាំមុន។

# អក្សរសរសេរកាត់

| | | |
|---|---|---|
| CAS | Cambodia Agriculture Survey | ការអង្កេតកសិកម្មកម្ពុជា |
| CIAS | Cambodia Inter-Censal Agriculture Survey | ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា |
| CSES | Cambodia Socio-Economic Survey | ការអង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា |
| FAO | Food and Agriculture Organization | អង្គការស្បៀងនិងកសិកម្ម |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| Ha | Hectare | ហិកតា |
| Kg | Kilograms | គីឡូក្រាម |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MOP | Ministry of Planning | ក្រសួងផែនការ |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| PPS | Probability Proportional to Size | ទំហំសមាមាត្រប្រហាក់ប្រហែល |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| TC | Technical Committee | គណៈកម្មការបច្ចេកទេស |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| USD | United States Dollar | ដុល្លារអាមេរិក |

# ជំពូកទី១៖ វិសាលភាព ការគ្របដណ្តប់ និងការជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ នៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឡើងក្នុងឆ្នាំ២០២០-២០២១ គឺជាកិច្ចការស្ថិតិទូលំទូលាយមួយ សម្រាប់ប្រមូល និងចងក្រងព័ត៌មានស្តីពីការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ។ ទិន្នន័យដែលប្រមូលបាន និងដែលបង្កើតបានពីការអង្កេតនេះ នឹងមានប្រយោជន៍សម្រាប់ការរៀបចំផែនការ គោលនយោបាយ និងកម្មវិធីសម្រាប់ការអភិវឌ្ឍ និងការកែលម្អវិស័យកសិកម្ម និងជលផលក្នុងរាជរដ្ឋាភិបាលកម្ពុជា(RGC)។ នេះជាការអង្កេតកសិកម្មប្រចាំឆ្នាំលើកដំបូង បន្ទាប់ពីការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៩ នៅព្រះរាជាណាចក្រកម្ពុជា។

វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ(MOP) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF) ជាស្ថាប័នរដ្ឋាភិបាលដែលមានភារៈទទួលខុសត្រូវ និងដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២០ នេះ ។ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារៈកិច្ចធ្វើជំរឿន និងអង្កេត ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ចម្បងនៃទិន្នន័យដែលផលិតចេញពីការអង្កេតចន្លោះជំរឿននេះ។

## គោលបំណង

ការអង្កេតកសិកម្ម នេះមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីសកម្មភាពកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ដែលប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយ។ ជាពិសេសទិន្នន័យអង្កេតនេះនឹងមានប្រយោជន៍ក្នុង៖

១. ការផ្តល់បញ្ជីឈ្មោះមណ្ឌលជំរឿនដែលបានធ្វើបច្ចុប្បន្នភាពនៅក្នុងការអង្កេតកសិកម្ម។

២. ការផ្តល់ទិន្នន័យនៅថ្នាក់ប្រទេស និងតំបន់ ក្នុងនោះធាតុមួយចំនួនក៏មាននៅថ្នាក់ខេត្តផងដែរ។

៣. ការផ្តល់ទិន្នន័យអំពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃការកាន់កាប់កសិកម្មក្នុងប្រទេស ដូចជា ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រមទាំង ការធ្វើវារីវប្បកម្ម និងនេសាទ។

វិសាលភាពគ្របដណ្តប់ទាំងមូលនៃការអង្កេតនេះ មាននៅក្នុងកម្រងសំណួរលម្អិតដែលមាននៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។ ទិន្នន័យទាំងនេះបង្កើតសក្តានុពលសម្រាប់ការវិភាគទូលំទូលាយដែលអាចធំជាងវិសាលភាពនៃរបាយការណ៍នេះ។ គួរកត់សំគាល់ថា របាយការណ៍នេះរួមបញ្ចូលទិន្នន័យនៅថ្នាក់ជាតិ និងថ្នាក់តំបន់ជាមួយទិន្នន័យនៅថ្នាក់ខេត្តដែលមានជាតារាងនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (https://www.nis.gov.kh) ។

## វិធីសាស្ត្រ

ដោយសារជំងឺរាតត្បាតកូវីដ១៩ ដែលកំពុងកើតមាន និងឥទ្ធិពល ដែលអាចកើតចេញពីសកម្មភាពជ្រើសយកសំណាកគំរូសម្រាប់ការអង្កេតនេះ មកលើសុខភាពរបស់អ្នកឆ្លើយ និងអ្នកធ្វើការសម្ភាស វិធីសាស្ត្រទូទៅសម្រាប់ការអង្កេតកសិកម្មឆ្នាំ២០២០ គឺត្រូវប្រើប្រាស់ឡើងវិញនូវសំណាកគំរូពីអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ដោយប្រើជាសំណាកគំរូដដែល។ ទោះបីជាមានការថយចុះនៃចំនួនសំណាកគំរូ ដោយសារគ្រួសារខ្លះផ្លាស់ទី ឬបញ្ឈប់សកម្មភាពកសិកម្មក៏ដោយ វិធីសាស្ត្រនេះនៅតែអាចធ្វើការប្រមូលទិន្នន័យបានគ្រប់គ្រាន់ ដើម្បីសង្ខេបទិន្នន័យនៅថ្នាក់ជាតិ និងតំបន់ ជាមួយអថេរជាច្រើនដែលមាននៅថ្នាក់ខេត្តផងដែរ។

វិធីសាស្ត្រសម្រាប់ការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ គឺការជ្រើសយកសំណាកតំណាងពីមណ្ឌលជំរឿន (EA) នៅទូទាំងប្រទេសកម្ពុជា ពោលគឺ ពីក្នុងបញ្ជីឈ្មោះមណ្ឌលជំរឿនកសិកម្ម ឆ្នាំ២០១៣។ គ្រួសារនៅក្នុង EAs ទាំងនេះ ត្រូវបាន

ជ្រើសយក ដោយផ្អែកលើ សកម្មភាពកសិកម្មទាំងឡាយដែលមាន ដោយប្រើព័ត៌មាននេះជាមូលដ្ឋាន គ្រួសារកសិកម្មត្រូវបានចាត់ថ្នាក់ និងជ្រើសយកជាសំណាកគំរូ សម្រាប់ការប្រមូលទិន្នន័យបន្ថែម។ គ្រួសារដូចគ្នាទាំងនេះដែលបានសម្ភាសសម្រាប់អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ក៏ត្រូវបានទាក់ទងសម្រាប់ការសម្ភាសនៅក្នុងអង្កេតកសិកម្មឆ្នាំ២០២០ ផងដែរ ។ កិច្ចប្រឹងប្រែងប្រមូលទិន្នន័យក្នុងពេលដំណាលគ្នានេះ បានផ្តោតលើការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ដោយប្រើប្រាស់បញ្ជីអំពីប្រតិបត្តិការកសិកម្មមិនមែនជាគ្រួសារ និងបានពង្រីក ដោយផ្អែកលើមតិកែលម្អពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានជាតិស្ថិតិ ការិយាល័យខេត្ត និងភាគីពាក់ព័ន្ធផ្សេងទៀត។

អ្នកប្រមូលទិន្នន័យ រួមជាមួយអ្នកគ្រប់គ្រងទិន្នន័យនៅមូលដ្ឋាន ត្រូវបានជ្រើសរើសនៅគ្រប់ខេត្ត និងបណ្តុះបណ្តាលសម្រាប់កិច្ចការនេះ។ អ្នកប្រមូលទិន្នន័យ និងអ្នកគ្រប់គ្រងទាំងអស់ គឺជាបុគ្គលិកដែលមានស្រាប់នៃវិទ្យាស្ថានជាតិស្ថិតិ ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ កិច្ចប្រឹងប្រែងរួមគ្នារវាងក្រសួងទាំងពីរនេះ បានធ្វើឡើងនៅទូទាំងគម្រោងអង្កេតកសិកម្ម ដោយមន្ត្រីមកពីស្ថាប័នទាំងពីរ បានចូលរួមក្នុងការអង្កេតនេះតាមរយៈការប្រមូល និងការវិភាគទិន្នន័យ។

ការប្រមូលទិន្នន័យសម្រាប់ការអង្កេតនេះ បានធ្វើឡើងតាមរយៈបច្ចេកទេសសម្ភាសន៍ផ្ទាល់ដោយប្រើកុំព្យូទ័រជាជំនួយ (CAPI) ។ កម្រងសំណួរត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធី Survey Solutions របស់ធនាគារពិភពលោក ។ ការប្រើប្រាស់ CAPI សម្រាប់ការប្រមូលទិន្នន័យ បានផ្តល់អត្ថប្រយោជន៍ជាច្រើន រួមទាំង កាត់បន្ថយការចំណាយលើការបោះពុម្ពតារាងបញ្ជីសំណួរ មិនតម្រូវការឱ្យមានការវាយបញ្ចូលទិន្នន័យ និងអាចត្រួតពិនិត្យគុណភាព និងការវិភាគទិន្នន័យបានឆាប់រហ័ស និងកាន់តែប្រសើរ។

## វិសាលភាពនៃការអង្កេត

កម្រងសំណួរអង្កេតកសិកម្ម មាននៅក្នុងឧបសម្ព័ន្ធទី២ នៃរបាយការណ៍នេះ។ កម្រងសំណួរបានប្រមូលទិន្នន័យលើទិដ្ឋភាពមួយចំនួននៃការកាន់កាប់កសិកម្ម រួមទាំងព័ត៌មានប្រជាសាស្ត្រនៃអ្នកកាន់កាប់ សហកម្មសិទ្ធិករ និងសមាជិកគ្រួសារទាំងអស់ សកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី សកម្មភាពធ្វើវារីវប្បកម្ម និងនេសាទ សេដ្ឋកិច្ចក្នុងអំឡុងពេល១២ខែចុងក្រោយ កម្លាំងពលកម្មដែលប្រើប្រាស់នៅក្នុងការកាន់កាប់ និងព័ត៌មានអំពីលំនៅស្ថាន និងទ្រព្យសម្បត្តិគ្រួសារ។ សំណួរបន្ថែមថ្មីសម្រាប់អង្កេតកសិកម្មឆ្នាំ២០២០ គឺអំពីផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ១៩ ទៅលើសកម្មភាពកសិកម្ម ក៏ដូចជា កម្រិតអសន្តិសុខស្បៀងដែលគ្រួសារសម្ភាសបានជួបប្រទះផងដែរ។

## ទីតាំងភូមិសាស្ត្រគ្របដណ្តប់

គ្រួសារទាំងអស់ក្នុងប្រទេស លើកលែងគ្រួសារនៅក្នុងខណ្ឌចំនួនប្រាំមួយក្នុងរាជធានីភ្នំពេញ ក្រុងមួយក្នុងខេត្តព្រះសីហនុ និងក្រុងមួយក្នុងខេត្តសៀមរាប ដែលត្រូវបានស្គាល់ថាជាតំបន់ទីប្រជុំជន សុទ្ធតែមានសក្តានុពលក្នុងការជ្រើសយកនៅក្នុងសំណាកគំរូ នៃអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ និងបន្ទាប់មក ក្លាយជាសំណាកគំរូសម្រាប់ អង្កេតកសិកម្មឆ្នាំ២០២០។ សំណាកគំរូដើមដំបូងសម្រាប់អង្កេតកសិកម្មឆ្នាំ២០២០ មាន ១៥.៩៩៤ គ្រួសារកសិកម្ម ដែលជាគ្រួសារត្រូវបានសម្ភាសសម្រាប់អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ។

បន្ថែមពីលើកិច្ចប្រឹងប្រែងប្រមូលទិន្នន័យតាមគ្រួសារ ក៏មានកិច្ចប្រឹងប្រែងប្រមូលទិន្នន័យដាច់ដោយឡែក ដែលផ្តោតលើសហគ្រាសកសិកម្មខ្នាតធំដែលដំណើរការជាក្រុមហ៊ុន សាជីវកម្ម សហគមន៍ ស្ថាប័នរដ្ឋាភិបាល និងឯកជន ដែលហៅថា (ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ) នៅក្នុងផ្នែកមិនមែនគ្រួសារផងដែរ ។ តារាងបញ្ជីឈ្មោះនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ដែលមានការកាន់កាប់ប្រមាណ ២៨៥ ។ ដោយហេតុថា ការកាន់កាប់មួយចំនួនពុំមានដំណើរការអាជីវកម្ម

ឡើយក្នុងអំឡុងពេលថ្ងៃខែឆ្នាំយោង ដូច្នេះការប្រមូលទិន្នន័យបានធ្វើឡើងពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំបានត្រឹមចំនួន ១៩៧ ប៉ុណ្ណោះ។

## រយៈពេលនៃការអង្កេត និងកាលបរិច្ឆេទយោង

ការអង្កេតកសិកម្មឆ្នាំ២០២០ ត្រូវបានធ្វើឡើងជាពីរដំណាក់កាលៈ ដំណាក់កាលទីមួយ ផ្តោតលើការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ដោយមានការប្រមូលទិន្នន័យចាប់ពីថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២១។ ដំណាក់កាលទី២ ជាការសម្ភាសគ្រួសារកសិកម្ម ដែលបានធ្វើឡើងក្នុងអំឡុងពេលពីថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២០ ដល់ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០២១។

រយៈពេល ១២ ខែមុនថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២០ (ពោលគឺ ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០) ត្រូវបានប្រើជាអំឡុងពេលយោងសម្រាប់ការប្រមូលទិន្នន័យនេះ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ធាតុមួយចំនួន អំឡុងពេលយោងមានភាពខុសពីរយៈពេលដែលបានបញ្ជាក់ អាស្រ័យហេតុនេះត្រូវបានចង្អុលបង្ហាញដាច់ដោយឡែកសម្រាប់ទិន្នន័យអំពីធាតុនោះ ទៅតាមការចាំបាច់។ ឧទាហរណ៍ សម្រាប់បសុសត្វមួយចំនួន ទិន្នន័យអំពីចំនួនសត្វនៅក្នុងការកាន់កាប់ត្រូវបានកត់ត្រា ដោយគិតយកថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០២០ ជាកាលបរិច្ឆេទយោង។

## តារាងបញ្ជីសំណាកគំរូ

ការអង្កេតកសិកម្មឆ្នាំ២០២០ បានប្រើប្រាស់សំណាកគំរូដូចគ្នានឹងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩។ ការអង្កេតអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ បានប្រើបញ្ជីឈ្មោះមណ្ឌលជំរឿននៃជំរឿនកសិកម្មឆ្នាំ២០១៣ ។ បញ្ជីឈ្មោះមណ្ឌលជំរឿននេះមានប្រមាណ ១៤.០០០ភូមិ និង ៣៥.០០ មណ្ឌលជំរឿន(EAs)។ សម្រាប់ភូមិនីមួយៗ មានការប្រមូលយកព័ត៌មានដូចតទៅ៖ ខេត្ត ស្រុក ឃុំ ស្ថានភាព (ជនបទ/ទីក្រុង) ចំនួន EA និងចំនួនគ្រួសារ។ ប្រជាជនជាគោលដៅ គឺគ្រួសារដែលប្រកបរបរកសិកម្មនេសាទ និង/ឬ វារីវប្បកម្ម។ មានចំនួនភូមិទីជនបទតិចតួចដែលស្ថិតនៅក្នុងក្រុង/ស្រុកទីប្រជុំជនត្រូវបានផាត់ចេញ

- ខេត្តព្រះសីហនុ ក្រុងព្រះសីហនុ
- ខេត្តសៀមរាប ក្រុងសៀមរាប
- រាជធានីភ្នំពេញ ខណ្ឌចំការមន
- រាជធានីភ្នំពេញ ខណ្ឌដូនពេញ
- រាជធានីភ្នំពេញ ខណ្ឌ៧មករា
- រាជធានីភ្នំពេញ ខណ្ឌទួលគោក
- រាជធានីភ្នំពេញ ខណ្ឌឫស្សីកែវ
- រាជធានីភ្នំពេញ ខណ្ឌច្បារអំពៅ

ការគណនាចំនួនគ្រួសារជនបទក្នុងខេត្តនីមួយៗបានធ្វើឡើង ដោយបូកចំនួនគ្រួសារនៅក្នុងភូមិដែលត្រូវបានចាត់ជាជនបទ ដោយសារមិនដឹងពីចំនួនគ្រួសារជនបទនៅក្នុង EA។ ការចុះបញ្ជីនៅក្នុង EA នីមួយៗសម្រាប់យកសំណាកគំរូ ត្រូវបានធ្វើឡើងសម្រាប់អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ក្នុងបំណងកំណត់អត្តសញ្ញាណប្រជាជនជាគោលដៅពោលគឺ គ្រួសារដែលពាក់ព័ន្ធក្នុងកសិកម្ម។

សម្រាប់ការអង្កេតនេះ ពុំមានការកំណត់កម្រិតអប្បបរមានៃការពាក់ព័ន្ធរបស់គ្រួសារសម្រាប់ការចាត់បញ្ចូលជាគ្រួសារកសិកម្មឡើយ។ ចំណុចនេះខុសគ្នាខ្លះពីនីតិវិធីដែលបានប្រើក្នុងជំរឿនកសិកម្មឆ្នាំ២០១៣ ដែលការសម្ភាសបានធ្វើចំពោះតែ

គ្រួសារដែលបានដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ ហិកតា និង/ឬមានបសុសត្វធំចំនួន ២ និង/ឬ បសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សីចំនួន ២៥ ក្បាលយ៉ាងតិច។ ក្នុងអំឡុងពេលអង្កេតកសិកម្មឆ្នាំ២០២០ គ្រួសារកសិកម្មចំនួន ៩៨,៨៦% ត្រូវនឹងនិយមន័យដែលបានប្រើប្រាស់កន្លងមក ដើម្បីកំណត់យកគ្រួសារកសិកម្ម។ នីតិវិធីដែលបានប្រើនៅក្នុងអង្កេតកសិកម្មដោយពុំមានកំណត់លើទំហំផ្ទៃដីអប្បបរមា ឬ ចំនួនបសុសត្វ ឬបសុបក្សី បានផ្តល់ឱកាសសម្រាប់ការបញ្ចូលគ្រួសារកសិកម្មខ្នាតតូច ក្នុងការជ្រើសរើសសម្រាប់ការអង្កេតនេះ។ ទោះជាយ៉ាងណាក៏ដោយ ដោយផ្អែកលើនីតិវិធីនៃការជ្រើសយកសំណាកដូចបានរៀបរាប់ខាងក្រោម ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារដែលមានផ្ទៃដីធំ ឬចំនួនបសុសត្វ ឬបសុបក្សីច្រើនត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ចូលក្នុងក្រុមសំណាកផ្សេងគ្នា ដើម្បីអាចជ្រើសយកបានគ្រួសារកសិកម្មទាំងនោះ។

## វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មឆ្នាំ២០២០ បានប្រើវិធីសាស្ត្រអង្កេតសំណាកគំរូដដែល ដោយប្រើប្រាស់សំណាកគ្រួសារកសិកម្មនៅក្នុងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ដែលបានស្រង់ចេញតាមរយៈនីតិវិធីជ្រើសយកសំណាកគូរជាពីរដំណាក់កាលដោយយក EAs ជាឯកត្តាបឋម និងគ្រួសារដែលធ្វើសកម្មភាពកសិកម្មជាឯកត្តាបន្ទាប់បន្សំ។ នៅក្នុងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ មានការជ្រើសយក EAs ចំនួន ១.៣៥០ និងក្នុង EA នីមួយៗ ជ្រើសយក១២ គ្រួសារកសិកម្ម សម្រាប់ទំហំសំណាកដែលគ្រោងទុកសរុប ១៦.០០០គ្រួសារ។ ចំនួនមណ្ឌលជំរឿន ១.៣៥០ ត្រូវបានជ្រើសរើសចែកជន្សពីគ្រប់រាជធានីខេត្ត តាមសមាមាត្រនៃចំនួនគ្រួសារជនបទក្នុងខេត្តទាំងនោះ ។ ដោយសារនៅរាជធានីភ្នំពេញពុំមានភូមិជនបទ មណ្ឌលជំរឿនចំនួន ៥០ ស្មើនឹង ៦០.០០០ គ្រួសារជនបទ ត្រូវបានជ្រើសរើសនៅរាជធានីភ្នំពេញ។ មណ្ឌលជំរឿនចំនួន ១.៣២០ ផ្សេងទៀតត្រូវបានជ្រើសរើសនៅខេត្តនានាផ្សេងទៀត។ តារាងទី១ ខាងក្រោម បង្ហាញពីការជ្រើសរើសសំណាកគំរូសម្រាប់ អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩។ ដើម្បីជ្រើសយក EAs នៅក្នុងខេត្តនីមួយៗ ឈ្មោះភូមិនានាត្រូវបានចុះនៅតាមស្រុក បន្ទាប់មកតាមឃុំ និងតាមស្ថានភាពភូមិ (ជនបទ-ទីក្រុង) និងបន្ទាប់មកមានការស្រង់យកសំណាកជាលក្ខណៈប្រព័ន្ធដោយយកទំហំ (ចំនួនគ្រួសារ) គិតតាមសមាមាត្រប្រហាក់ប្រហែល។

សេចក្តីពិស្តារបន្ថែមអំពីវិធីសាស្ត្រជ្រើសយកសំណាកសម្រាប់អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ មានបញ្ចូលក្នុងឧបសម្ព័ន្ធទី៣ នៃរបាយការណ៍ចុងក្រោយអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ដែលមាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។ សំណាកគំរូគ្រួសារសម្រាប់អង្កេតកសិកម្មឆ្នាំ២០២០ ធ្វើឡើងដោយគ្រួសារកសិកម្មដែលស្រង់ពីការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ទាំងស្រុង។ គ្រួសារខ្លះមិនអាចទាក់ទងបានទេ ខ្លះឈប់ធ្វើកសិកម្ម ខ្លះទៀតបានផ្លាស់ទីទៅភូមិ/ស្រុកផ្សេង ឬមិនឆ្លើយតបទៅនឹងកម្រងសំណួរ។ ដោយសារការថយចុះនៃចំនួនសំណាកគំរូ និងអត្រាមិនឆ្លើយតបនេះទំហំសំណាកគំរូដែលទទួលបានបង្ហាញនៅក្នុងជួរឈរខាងស្តាំបំផុតនៃតារាងទី១ខាងក្រោម។

## តារាងទី១.១ ការជ្រើសរើសសំណាកគំរូ

| រាជធានី/ខេត្ត | ចំនួនសរុបនៃគ្រួសារជនបទ/កសិកម្មពីជំរឿនកសិកម្មឆ្នាំ២០១៣ | ចំនួន EA ដែលបានជ្រើសយកសំណាកគំរូ (PSUs) សម្រាប់ CIAS ២០១៩ | ចំនួនគ្រួសារកសិកម្មដែលបានជ្រើសយកសំណាកគំរូសម្រាប់ CIAS ២០១៩ | ចំនួនគ្រួសារកសិកម្មដែលបានសម្ភាសសម្រាប់ CAS ២០២០ |
|---|---|---|---|---|
| **តំបន់វាលទំនាប** | 1.252.491 | 615 | 7.174 | 6.652 |
| ភ្នំពេញ | ប៉ាន់ស្មាន 60.000 | 50 | 394 | 342 |
| ព្រៃវែង | 268.473 | 127 | 1.524 | 1.406 |
| ស្វាយរៀង | 124.656 | 59 | 708 | 673 |
| តាកែវ | 206.084 | 98 | 1.176 | 1.110 |
| ត្បូងឃ្មុំ | 167.628 | 79 | 948 | 863 |
| កណ្ដាល | 205.812 | 98 | 1.176 | 1.094 |
| កំពង់ចាម | 219.838 | 104 | 1.248 | 1.164 |
| **តំបន់បឹងទន្លេសាប** | 916.840 | 444 | 5.328 | 4.820 |
| ប៉ៃលិន | 7.575 | 12 | 144 | 133 |
| បន្ទាយមានជ័យ | 122.230 | 58 | 696 | 607 |
| បាត់ដំបង | 209.719 | 99 | 1.188 | 1.078 |
| ឧត្ដរមានជ័យ | 43.614 | 21 | 252 | 212 |
| សៀមរាប | 163.620 | 78 | 936 | 871 |
| កំពង់ឆ្នាំង | 119.924 | 57 | 684 | 644 |
| កំពង់ធំ | 153.243 | 73 | 876 | 796 |
| ពោធិ៍សាត់ | 96.915 | 46 | 552 | 479 |
| **តំបន់ឆ្នេរសមុទ្រ** | 178.760 | 105 | 1.260 | 1.141 |
| កំពត | 135.273 | 64 | 768 | 702 |
| កែប | 4.316 | 10 | 120 | 111 |
| កោះកុង | 17.483 | 15 | 180 | 160 |
| ព្រះសីហនុ | 21.688 | 16 | 192 | 168 |
| **តំបន់ភ្នំ និងខ្ពង់រាប** | 372.578 | 186 | 2,232 | 2,109 |
| កំពង់ស្ពឺ | 164.840 | 78 | 936 | 897 |
| ក្រចេះ | 79.043 | 38 | 456 | 426 |
| មណ្ឌលគិរី | 16.413 | 14 | 168 | 154 |
| ព្រះវិហារ | 49.075 | 23 | 276 | 273 |
| រតនៈគិរី | 36.904 | 17 | 204 | 182 |
| ស្ទឹងត្រែង | 26.303 | 16 | 192 | 177 |
| **សរុប** | **2.720.669** | **1.350** | **15.994** | **14.722** |

## មេគុណ និងការប៉ាន់ស្មាន

នីតិវិធីនៃការជ្រើសរើសសំណាគំរូ និងការចាត់ថ្នាក់ ដូចដែលបានរៀបរាប់ខាងលើ និងក្នុងឧបសម្ព័ន្ធទី៣ នៃរបាយការណ៍ចុងក្រោយអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ បានបណ្ដាលឲ្យមានប្រូបាប៊ីលីតេនៃការជ្រើសរើសគ្រួសារកសិកម្មក្នុងកម្រិតៗខុសគ្នា។ ដោយពិចារណា ចំណុចនេះ ការគណនាមេគុណត្រូវបានធ្វើឡើង សម្រាប់គ្រួសារកសិកម្មនីមួយៗនៅក្នុងសំណាក និងបានអនុវត្តចំពោះទិន្នន័យដែលបានរាយការណ៍សម្រាប់កំណត់គ្រានោះ។ បន្ទាប់មកមេគុណសម្រាប់អង្កេតកសិកម្មឆ្នាំ ២០២០ ត្រូវបានកែតំរូវសម្រាប់ករណីគ្មានចម្លើយ និងការខូចគុណភាព ហើយបានក្រិតតាមខ្នាត ដោយប្រើចំនួនគ្រួសារកសិកម្មតាមខេត្ត ដែលទទួលបានតាមរយៈជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩។ ជាចុងក្រោយ ទិន្នន័យដែលបានរាយការណ៍នេះ ត្រូវបានបូកសរុបនៅកម្រិតខេត្ត តំបន់ និងថ្នាក់ជាតិ។ ព័ត៌មានលម្អិតអំពីការគណនាមេគុណដើមដំបូង មានផ្ដល់នៅក្នុងឧបសម្ព័ន្ធទី៤ នៃរបាយការណ៍ចុងក្រោយអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ដែលមាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

## វិធីសាស្ត្រសម្រាប់សហគ្រាសកសិកម្មខ្នាតធំ

បញ្ជីឈ្មោះមណ្ឌលជំរឿនសម្រាប់ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ត្រូវបានបង្កើតឡើង ដោយផ្អែកតាមបញ្ជីដែលបានពីស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា រួមទាំង នាយកដ្ឋាននានានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។ បញ្ជីឈ្មោះមណ្ឌលជំរឿន ក៏បញ្ចូលផងដែរនូវសហគ្រាសធំៗដែលត្រូវបានសម្ភាសក្នុងអំឡុងជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៣ និងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩។ ប្រមាណ ២៨៥សហគ្រាសដែលអាចជាការកាន់កាប់កសិកម្មមិនមែនគ្រួសារ ត្រូវបានរួមបញ្ចូលនៅក្នុងបញ្ជីឈ្មោះមណ្ឌលជំរឿន។ បញ្ជីឈ្មោះមណ្ឌលជំរឿននេះត្រូវបានរៀបចំឡើង តាមរយៈការទាក់ទងទៅសហគ្រាសនីមួយៗទាំងនេះ សម្រាប់ការប្រមូលទិន្នន័យ។ ទិន្នន័យពីការកាន់កាប់ទាំងនេះ ត្រូវបានប្រមូលយកពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០២០ ដល់ថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០២១។ ក្នុងចំណោមការកាន់កាប់ចំនួន ២៨៥ ដែលបានទាក់ទងក្នុងអំឡុងពេលនៃកិច្ចប្រឹងប្រែងនេះ មានការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំត្រឹមចំនួន១៩៧ តែប៉ុណ្ណោះ។

## នីតិវិធីនៃការអង្កេត

ទិន្នន័យទាំងអស់នៅក្នុងអង្កេតកសិកម្មឆ្នាំ២០២០ ត្រូវបានប្រមូលយកតាមរយៈការសម្ភាសជាលក្ខណៈបុគ្គល ដោយប្រើកុំព្យូទ័រជាជំនួយ ដោយក្រុមអ្នកប្រមូលទិន្នន័យ និងអ្នកគ្រប់គ្រងដោយផ្ទាល់ ដែលបានទទួលការបណ្ដុះបណ្ដាល និងដែលធ្វើការសម្ភាសបុគ្គលអ្នកឆ្លើយដែលមានចំណេះដឹងអំពីការកាន់កាប់កសិកម្ម។ អ្នកឆ្លើយសំណួរ គឺជាមនុស្សពេញវ័យដែលមានចំណេះដឹងអំពីសកម្មភាពនៃការកាន់កាប់កសិកម្ម។ អ្នកឆ្លើយដែលមានគុណវុឌ្ឍិខ្ពស់បំផុត គឺអ្នកកាន់កាប់កសិកម្ម។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីគាត់អវត្តមាន សហព័ទ្ធ ឬសមាជិកគ្រួសារដែលមានចំណេះដឹង ក៏អាចដើរតួជាអ្នកឆ្លើយផងដែរ។ មានការណែនាំថា ពុំត្រូវធ្វើសម្ភាស ឬសួរព័ត៌មានពីអ្នកជិតខាង ឬគ្រួសារផ្សេងទៀតឡើយ អំពីការកាន់កាប់ដែលកំពុងស្ថិតក្នុងការអង្កេតនេះ។

ទិន្នន័យក្នុងការអង្កេតនេះ ត្រូវបានប្រមូលយក ដោយប្រើកម្រងសំណួរដែលណែនាំនៅក្នុងឯកសារណែនាំអ្នកប្រមូលទិន្នន័យនៃអង្កេតកសិកម្ម ដែលចែងពីទស្សនទានលម្អិត និយមន័យ និងនីតិវិធីដែលត្រូវអនុវត្ត សម្រាប់ការប្រមូលទិន្នន័យ។ សេចក្ដីព្រាងកម្រងសំណួរ និងឯកសារណែនាំ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍អំពីតម្រូវការទិន្នន័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិធីសាស្ត្រ AGRISurvey។ កម្រងសំណួរ និងឯកសារណែនាំស្ដីពីការប្រមូលទិន្នន័យនៃ

អង្កេតកសិកម្ម ត្រូវបានកែសម្រួល ដោយផ្អែកលើបទពិសោធន៍ និងលទ្ធផលដែលទទួលបានក្នុងអំឡុងពេលពីរជុំនៃលំហាត់សាកល្បង។ ឯកសារណែនាំអ្នកប្រមូលទិន្នន័យ នៃអង្កេតកសិកម្ម ត្រូវបានបំពេញបន្ថែមដោយ ការត្រួតពិនិត្យលើភាពស៊ីសង្វាក់គ្នានៃទិន្នន័យ ដែលធ្វើឡើងពីចម្ងាយដោយក្រុមអ្នកគ្រប់គ្រងទិន្នន័យ និងនៅក្នុងដំណើរការផ្ទៀងផ្ទាត់ទិន្នន័យជាបន្តបន្ទាប់នៅពេលក្រោយមក។

ទិន្នន័យដែលប្រមូលបានទាំងអស់ ត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេ (Cloud) របស់ធនាគារពិភពលោក ដោយឥតគិតថ្លៃ។ អ្នកគ្រប់គ្រងម៉ាស៊ីនមេអាចទាញយកទិន្នន័យនេះក្នុងទម្រង់ផ្សេងៗ នៅពេលណាមួយ ក្នុងអំឡុងពេលប្រមូលទិន្នន័យ និងរហូតដល់ខែមិថុនា ឆ្នាំ ២០២០ នៅពេលដែលម៉ាស៊ីនមេត្រូវបានបិទ។

## យន្តការជំនួយក្នុងការសម្ភាសន៍

មុននឹងចាប់ផ្តើមចុះប្រមូលទិន្នន័យតាមមូលដ្ឋាន គម្រោងអង្កេតកសិកម្មឆ្នាំ២០២០ បានទទួលលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចែកជូនដល់មន្ត្រីនៅមូលដ្ឋាន និងអ្នកតបសម្ភាសន៍ទៅតាមការចាំបាច់ ដើម្បីទទួលកិច្ចសហការពីគ្រប់គ្រួសារសម្ភាសន៍ និងសហគ្រាសនានាដែលធ្វើសកម្មភាពកសិកម្មនៅក្នុងប្រទេស។

## ប្រតិបត្តិការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យទាំងអស់សម្រាប់អង្កេតកសិកម្ម បានធ្វើឡើងដោយអ្នកប្រមូលទិន្នន័យដែលបានទទួលការបណ្តុះបណ្តាល និងដែលត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីដែលមាននៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នៃវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើការសម្ភាសជម្រុះ។ ប្រតិបត្តិការនៅតាមរាជធានី/ខេត្ត រួមមានការបណ្តុះបណ្តាលអ្នកគ្រប់គ្រង និងអ្នកប្រមូលទិន្នន័យទាំងអស់ អំពីវិធីប្រមូលទិន្នន័យ និងការត្រួតពិនិត្យ។ មន្ត្រីអង្កេតកសិកម្ម ដែលត្រូវបំពេញភារកិច្ចនៅថ្នាក់កណ្តាល និងនៅតាមភូមិសាស្ត្រ បានទទួលការបណ្តុះបណ្តាល មុនពេលអនុវត្តដំណើរការប្រមូលទិន្នន័យ និងត្រួតពិនិត្យ។ ដោយសារអង្កេតកសិកម្ម ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ សកម្មភាពបណ្តុះបណ្តាលបានគ្របដណ្តប់លើកិច្ចការទាំងពីរបែបនេះ។ ការបណ្តុះបណ្តាលបានធ្វើឡើងជាពីរកម្រិត ដាច់ដោយឡែកពីគ្នា៖ (ក) ការបណ្តុះបណ្តាលគ្រូបង្គោល ដែលជាមន្ត្រីការិយាល័យកណ្តាល នៃវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដែលបម្រើការជាអ្នកគ្រប់គ្រងទិន្នន័យ អ្នកគ្រប់គ្រងតាមភូមិសាស្ត្រ និងអ្នកប្រមូលទិន្នន័យពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ និង (ខ) ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ។ មន្ត្រីជំនាញតាមភូមិសាស្ត្រទាំងអស់ ដែលរួមទាំងអ្នកគ្រប់គ្រងនៅគ្រប់កម្រិត បានទទួលការបណ្តុះបណ្តាលទូលំទូលាយអំពីទស្សនទាន និយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

អ្នកគ្រប់គ្រងទិន្នន័យមានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ។ សម្រាប់គម្រោងនេះទាំងមូលមានអ្នកគ្រប់គ្រងទិន្នន័យចំនួន ៤៦នាក់ ដែលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ។ អ្នកគ្រប់គ្រងតាមភូមិសាស្ត្រ មានភារៈទទួលខុសត្រូវក្នុងការជួយអ្នកប្រមូលទិន្នន័យ ក្នុងការដោះស្រាយបញ្ហានៅតាមភូមិសាស្ត្រ លើកទឹកចិត្តឱ្យមានទំនាក់ទំនងល្អជាមួយបុគ្គលទាក់ទងនៅតាមភូមិ និងជំរុញកិច្ចសហប្រតិបត្តិការពីគ្រួសារកសិកម្មដែលជាអ្នកផ្តល់ចម្លើយ។ សម្រាប់គម្រោងនេះ មានអ្នកគ្រប់គ្រងតាមភូមិសាស្ត្រចំនួន ៤៦ នាក់ ក្នុងនោះ ២៤ នាក់មកពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ២២ នាក់មកពី វិទ្យាស្ថានជាតិស្ថិតិ។ អ្នកប្រមូលទិន្នន័យសរុបទាំងអស់មាន ៣៣៧ នាក់ ក្នុងនោះ ១៩៧ នាក់មកពីវិទ្យាស្ថានជាតិស្ថិតិ

និង ១៤០ នាក់ជាមន្ត្រីថ្នាក់ខេត្ត និងស្រុក នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ត្រីសរុបចំនួន ៤២៩ នាក់បានចូលរួមក្នុងការចុះប្រមូលទិន្នន័យ ប៉ុន្តែមានមន្ត្រីចំនួនច្រើនជាងនេះ ដែលបានទទួលការបណ្តុះបណ្តាល ដោយមួយចំនួនត្រូវបានរក្សាទុកជាមន្ត្រីបម្រុងសម្រាប់គម្រោងកសិកម្មនេះ។ លើសពីនេះទៀត មន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ ចំនួន ១១ នាក់នៅរាជធានីភ្នំពេញ បានទទួលការបណ្តុះបណ្តាលនៅក្នុងការិយាល័យកណ្តាល អំពីឧបករណ៍ដោះស្រាយការអង្កេត (Survey Solutions) ដែលត្រូវអនុវត្តដំណើរការអនុម័តចុងក្រោយលើលទ្ធផលដែលទទួលបានពីការសម្ភាស។

លទ្ធផលត្រឹមត្រូវចុងក្រោយនៃអង្កេតកសិកម្ម អាស្រ័យលើគុណភាពនៃការប្រមូលទិន្នន័យពីគ្រួសារ និងពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលបានកត់ត្រា។ ទោះបីជាការបណ្តុះបណ្តាលបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយដំណើរការទិន្នន័យបានប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពក៏ដោយ ប្រសិនបើក្នុងអំឡុងពេលដំណើរការប្រមូលទិន្នន័យ គ្មានការត្រួតពិនិត្យគុណភាពដោយប្រសិទ្ធភាពទេនោះ ទិន្នន័យចុងក្រោយនឹងនៅតែមានគុណភាពទាប។ នៅក្នុងអង្កេតកសិកម្ម មានការត្រួតពិនិត្យ និងមធ្យោបាយទំនាក់ទំនងជាច្រើនកម្រិត ដូចដែលបានចែងលម្អិតក្នុងឯកសារណែនាំសម្រាប់អ្នកប្រមូលទិន្នន័យនៃអង្កេតកសិកម្ម។ តួនាទីសម្រាប់ការត្រួតពិនិត្យ និងការទាក់ទង ត្រូវបានបង្កើតឡើង រួមជាមួយគោលការណ៍ណែនាំទូលំទូលាយ ដែលរំលេចចេញសកម្មភាពខុសៗគ្នា និងនីតិវិធីត្រួតពិនិត្យគុណភាព ដើម្បីតាមដានវឌ្ឍនភាពនៃការកត់ត្រាទិន្នន័យឲ្យបានត្រឹមត្រូវសម្រាប់ អង្កេតកសិកម្ម និងដើម្បីអាចរកឃើញបញ្ហាណាមួយភ្លាមៗនៅក្នុងពេលចុះប្រមូលទិន្នន័យ។ ការប្រើប្រាស់ CAPI ប្រកបដោយភាពច្នៃប្រឌិត សម្រាប់ប្រមូលទិន្នន័យ អាចអនុញ្ញាតឱ្យមានការត្រួតពិនិត្យទាន់ពេលវេលានូវលំហូរទិន្នន័យ និងគុណភាពទិន្នន័យ។

## ការកែច្នៃទិន្នន័យ

ក្រោយពេលប្រមូលទិន្នន័យអង្កេតពីគ្រួសារកសិកម្ម អ្នកប្រមូលទិន្នន័យបញ្ជូនកម្រងសំណួរដែលបានបំពេញរួចតាមកម្មវិធី Survey Solutions ទៅកាន់អ្នកគ្រប់គ្រងទិន្នន័យរបស់ខ្លួន ដែលត្រូវធ្វើការពិនិត្យយ៉ាងហ្មត់ចត់។ ប្រសិនបើរកឃើញកំហុស ឬទិន្នន័យដែលគួរសង្ស័យ អ្នកគ្រប់គ្រងទិន្នន័យនឹងបញ្ជូណ កម្រងសំណួរនោះទៅអ្នកចុះសម្ភាសន៍នោះវិញ ដើម្បីដោះស្រាយបញ្ហានោះជាមួយអ្នកតបសម្ភាសន៍ តាមការចាំបាច់ ហើយកំណត់ត្រាដែលបានកែតម្រូវ នឹងត្រូវបញ្ជូនមកអ្នកគ្រប់គ្រងទិន្នន័យឡើងវិញ។ នៅពេលអ្នកគ្រប់គ្រងទិន្នន័យបានផ្ទៀងផ្ទាត់កំណត់ត្រាត្រឹមត្រូវហើយ ពួកគាត់នឹងអនុម័ត សម្រាប់ការត្រួតពិនិត្យចុងក្រោយដោយមន្ត្រីនៅការិយាល័យកណ្តាល។

ទីស្នាក់ការកណ្តាល ជាកន្លែងទទួលកម្រងសំណួរដែលបានបំពេញរួចហើយ បន្ទាប់ពីបានអនុម័តដោយអ្នកគ្រប់គ្រងទិន្នន័យ។ ប្រសិនបើក្នុងអំឡុងពេលត្រួតពិនិត្យនេះ ទីស្នាក់ការកណ្តាលរកឃើញបញ្ហាណាមួយ ឬទិន្នន័យគួរឱ្យសង្ស័យ កំណត់ត្រានោះអាចត្រូវបង្វែរមកអ្នកប្រមូលទិន្នន័យវិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ឬកែតម្រូវ តាមការចាំបាច់។ កំណត់ត្រាអំពីរបៀបពិនិត្យ ទិន្នន័យក្នុងកម្រងសំណួរដើម្បីរកមើលធាតុគួរឱ្យសង្ស័យ ឬ តួលេខមិនប្រក្រតី ត្រូវបានបញ្ជូនមកអ្នកគ្រប់គ្រងទិន្នន័យ និងមន្ត្រីនៅការិយាល័យកណ្តាល។

ការពិនិត្យទិន្នន័យ និងការគណនាតួលេខប៉ាន់ប្រមាណនៅក្នុងការអង្កេតនេះ បានធ្វើឡើងដោយប្រើកម្មវិធី RStudio ការពិនិត្យសុពលភាពនៃទិន្នន័យបានចាប់ផ្តើម តាំងពីពេលដែលកម្រងសំណួរត្រូវបានធ្វើឡើងនៅក្នុង (CAPI) ដោយសារកម្មវិធី Survey Solutions អាចឱ្យមានការត្រួតពិនិត្យភាពស៊ីសង្វាក់គ្នានៅក្នុងឧបករណ៍ប្រមូលទិន្នន័យ។ ការត្រួតពិនិត្យភាពស៊ីសង្វាក់ជាបន្ថែម នឹងត្រូវអនុវត្តរួចភ្លាមៗ នៅក្នុងដំណាក់កាលប្រមូលទិន្នន័យ ក្នុងករណីដែលមានការបញ្ជូនកំណត់ត្រាមកអ្នកប្រមូលទិន្នន័យវិញ ដោយធ្វើការប្រៀបធៀបរបាយការណ៍ទៅនឹងទិន្នន័យជំរឿនពីមុន ការវាយតម្លៃកម្រិតនៃភាពសមហេតុផលសម្រាប់ធាតុមួយចំនួន និងការផ្ទៀងផ្ទាត់កំណត់ត្រាមិនប្រក្រតីនានា ជាមួយអ្នកប្រមូលទិន្នន័យនិង/ឬអ្នកឆ្លើយ។ លើសពី

នេះ នៅពេលសំអាតទិន្នន័យ មានការអនុវត្តជំហានមួយទៀត ដើម្បីបញ្ចូលតួលេខដែលបាត់ ដោយសារគ្មានចម្លើយក្នុងពេលសម្ភាស ដោយប្រើតួលេខជំនួស។

## បទដ្ឋាននៃការបោះពុម្ពផ្សាយ

ក្នុងការរៀបចំការបោះពុម្ពជារបាយកាណ៍ចុងក្រោយនេះ មានការបង្កើតស្តង់ដារសម្រាប់ការរៀបចំតារាងទិន្នន័យដែលមាននៅក្នុងឧបសម្ព័ន្ធទី១ ។ ស្តង់ដារទាំងនេះមានដូចជា៖

- តួលេខទាំងអស់ដែលទាក់ទងនឹងចំនួនគ្រួសារ ត្រូវបានបង្គត់ ទៅរកតួលេខជិតបំផុតគិតជាពាន់ ហើយតួលេខអំពីចំនួនគ្រួសារត្រូវបានគិតជាពាន់។
- ភាគរយដែលបានគណនាតែងតែផ្អែកលើទិន្នន័យដើម ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការបង្គត់ តារាងមួយចំនួនដែលមានតួលេខជាភាគរយ អាចមានផលបូកសរុបមិនស្មើ ១០០ ភាគរយឡើយ។
- និមិត្តសញ្ញា (-) ត្រូវបានប្រើនៅក្នុងក្រឡាដែលមានតួលេខសូន្យ ឬការសង្កេតមួយចំនួនតូច តួលេខចំនួនគ្រួសារមិនបង្គត់ទៅអប្បបរមា ១.០០០ គ្រួសារ ឬ មានមេគុណបម្រែបម្រួលធំ (CV) ។ តួលេខណាដែលមាន CV ចាប់ពី ៣៣ ឡើងទៅ មិនត្រូវបានបោះពុម្ពឡើយ ហើយត្រូវបានតំណាងដោយនិមិត្តសញ្ញា (-)។ ដូចគ្នានេះដែរ ក្រឡាខ្លះអាចមាននិមិត្តសញ្ញា (-) ជាការបង្ហាញបន្ទាប់បន្សំ។ នៅក្នុងករណីទាំងនេះ ទិន្នន័យនេះមិនបរាជ័យនៅចំពោះមុខវិធាននៃការបង្ហាញព័ត៌មានបឋមឡើយ (ចំនួនគ្រួសារអប្បបរមា ឬ CV ខ្ពស់) ប៉ុន្តែនៅពេលដែលរួមបញ្ចូលជាមួយទិន្នន័យផ្សេងទៀត វានឹងអាចឱ្យមានការកំណត់អត្តសញ្ញាណក្រឡាដែលបង្ហាញព័ត៌មានបឋម។
- នៅតំបន់ខ្លះ ប្រសិនបើខេត្តជាច្រើនមានការសង្កេតតិចតួច (តិចជាង ៥០០គ្រួសារដែលរាយការណ៍) តួលេខទាំងនេះត្រូវបានបញ្ចូលទៅក្នុងក្រុម "ខេត្តរួមបញ្ចូលគ្នា" និងត្រូវបានបោះពុម្ពផ្សាយ ប្រសិនបើតួលេខទាំងនេះត្រូវនឹងស្តង់ដារបោះពុម្ព។

ស្តង់ដារខាងលើកំហិតលើការចេញផ្សាយទិន្នន័យដែលមានគុណភាពទាប ដោយសារតែមានការសង្កេតត្រឹមមួយចំនួនតូច នៅក្នុងខេត្ត ឬតំបន់ជាក់លាក់ណាមួយ ហើយដែលស្របតាមស្តង់ដាររាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិ។

## ដែនកំណត់នៃការអង្កេតកសិកម្ម

ដូចនៅក្នុងការអង្កេតសំណាកគំរូទាំងអស់ផងដែរ នៅក្នុងអង្កេតកសិកម្ម មានដែនកំណត់ចំពោះទិន្នន័យដែលផលិតបាន និងដែនកំណត់នៃការបកស្រាយ ឬការប្រៀបធៀបទិន្នន័យទាំងនេះទៅនឹងប្រភពទិន្នន័យជំនួស។ នៅពេលអ្នកអានប្រើប្រាស់ទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះ ប្រការសំខាន់គឺ ត្រូវចងចាំអំពីដែនកំណត់ខាងក្រោម៖

- ទិន្នន័យស្វ័យរាយការណ៍ ៖ អ្នកផ្តល់ចម្លើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានស្នើសុំឲ្យផ្តល់ព័ត៌មានអំពីការកាន់កាប់កសិកម្មនោះ។ ព័ត៌មានទាំងនេះអាចទទួលផលប៉ះពាល់ពីការចងចាំរបស់អ្នកផ្តល់ចម្លើយក្នុងអំឡុងពេលយោងលើប្រភេទសំណួរជាច្រើន ក្នុងកម្រងសំណួរ ដោយផ្តោតក្នុងរយៈពេល១២ ខែកន្លងមក ។
- ការទទួលបានទិន្នន័យ ៖ ទិន្នន័យស្វ័យរាយការណ៍ ក៏អាចរងការប៉ះពាល់បន្ថែម ក្នុងអំឡុងពេលយោងដោយផ្ទាល់ និងអំឡុងពេលប្រមូលទិន្នន័យផងដែរ។ ដោយសារពេលវេលាមានការយឺតយ៉ាវ ទើបការប្រមូលទិន្នន័យមានឧបសគ្គ រហូតដល់ជាច្រើនខែ ក្រោយអំឡុងពេលថ្ងៃយោង។

- ចំនួនដែលមានកម្រិតកំណត់ក្នុងបញ្ជីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ៖ ទោះបីជាមានការប្រឹងប្រែងយ៉ាងច្រើនដើម្បីទទួលបានព័ត៌មានអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំទាំងអស់នៅកម្ពុជាក៏ដោយ កិច្ចប្រឹងប្រែងប្រមូលទិន្នន័យ អាចស្រង់យកបានតែព័ត៌មានពីការកាន់កាប់កសិកម្មមិនមែនគ្រួសារត្រឹមចំនួន ១៩៧ ប៉ុណ្ណោះ។ តួលេខនេះទំនងជាទាបខ្លាំងណាស់ ដែលមិនអាចតំណាងឱ្យការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំនៅកម្ពុជាឡើយ។ កិច្ចប្រឹងប្រែងនឹងមានបន្ថែមទៀត ដើម្បីកែលម្អដំណើរការនេះសម្រាប់ការអង្កេតប្រចាំឆ្នាំ ទោះជាយ៉ាងណាក៏ដោយ ភាពជាតំណាងនៃទិន្នន័យអង្កេតកសិកម្ម សម្រាប់វិស័យកសិកម្មទាំងមូល អាចរងការប៉ះពាល់ដោយសារតែកម្រិតទាបនៃវិសាលភាពគ្របដណ្តប់លើផ្នែកមិនមែនគ្រួសារ។
- បញ្ជីឈ្មោះមណ្ឌលជំរឿនចាស់ហួសសម័យ៖ ដោយសារបញ្ជីឈ្មោះមណ្ឌលជំរឿនសម្រាប់ការអង្កេតនេះ មានតាំងពីឆ្នាំ ២០១៣ មកម្ល៉េះ ដូច្នេះចំនួនគ្រួសារនៅក្នុង EA អាចមិនត្រឹមត្រូវ ដែលប៉ះពាល់មកលើភាពជាក់លាក់នៃមេគុណសម្រាប់ពង្រីកការគណនា។ នេះជាមូលហេតុ ដែលតម្រូវឱ្យមានគណនាមេគុណឡើងវិញ សម្រាប់ការជ្រើសយកសំណាកគំរូ ដោយប្រើចំនួនកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅតាមខេត្ត ដែលបានមកពីជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩ ។
- កម្រងសំណួរ និងនីតិវិធីសម្ភាស៖ នៅក្នុងអង្កេតកសិកម្ម រាល់កិច្ចប្រឹងប្រែងដើម្បីបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ និងអ្នកគ្រប់គ្រង ដើម្បីប្រមូលទិន្នន័យ តាមរយៈដំណើរការដែលមានការរួបរួមគ្នាជាប្រព័ន្ធ។ ប្រយោគសំណួរ និងការប្រាស្រ័យទាក់ទងនៅក្នុងការសម្ភាស ត្រូវធ្វើឡើងតាមទម្រង់ឯកសណ្ឋាន ទោះជាយ៉ាងណាក៏ដោយ ការប្រព្រឹត្តផ្ទាល់ខ្លួនដែលឃ្លាតចាកពីស្តង់ដារទាំងនេះ អាចប៉ះពាល់ដល់ការឆ្លើយនៅក្នុងការអង្កេត និងមានឥទ្ធិពលលើលទ្ធផលចុងក្រោយ។
- កម្រិតអាចប្រៀបធៀបបាន៖ នីតិវិធីដែលប្រើដើម្បីសង្ខេបទិន្នន័យ CAS ២០២០ មានភាពខុសប្លែកគ្នាខ្លះពី នីតិវិធីដែលបានប្រើនៅក្នុងអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩។ ដោយសារទិន្នន័យជំរឿនទូទៅប្រជាជនកម្ពុជាពីឆ្នាំ ២០១៩ អាចរកបានក្នុងកំឡុងពេលសង្ខេបទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២០ ដូច្នេះទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីក្រិតទិន្នន័យអង្កេតចុងក្រោយ ដែលបណ្តាលឱ្យមានភាពខុសគ្នាមួយចំនួន នៅក្នុងការប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំ។ កិច្ចប្រឹងប្រែងនឹងមានអនុវត្តបន្ត ដើម្បីសង្ខេបឡើងវិញនូវទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ ដោយប្រើជំរឿនប្រជាជនកម្ពុជានាពេលថ្មីៗនេះ ហើយរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នភាពនឹងចេញផ្សាយនៅពេលក្រោយ។

ដូចដែលអាចឃើញនៅក្នុងជំពូកខាងក្រោម របាយការណ៍នេះនឹងផ្តោតលើទិន្នន័យថ្នាក់ជាតិ និងតំបន់តែប៉ុណ្ណោះ ដើម្បីកាត់បន្ថយពេលវេលាចាំបាច់សម្រាប់ការរៀបចំ និងប្រវែងរបាយការណ៍នេះ។ ទិន្នន័យកម្រិតខេត្តទាំងអស់នឹងត្រូវបានផ្តល់ជូននៅក្នុងឯកសារទិន្នន័យដែលមាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

## ជំពូកទី២៖ លក្ខណៈនៃការកាន់កាប់កសិកម្ម

ការអង្កេតកសិកម្ម ចាត់ទុកការកាន់កាប់កសិកម្មជាឯកត្តាសេដ្ឋកិច្ចក្រោមការគ្រប់គ្រងទោលតែមួយ ជាមួយសកម្មភាពកសិកម្ម ដែលមាន ការដាំដំណាំ ការចិញ្ចឹមបសុសត្វ ឬបសុបក្សី និងការធ្វើវារីវប្បកម្ម ឬការនេសាទ។ ការកាន់កាប់កសិកម្មអាចរាប់បញ្ចូល ការដាំដំណាំ ការចិញ្ចឹមបសុសត្វ/បសុបក្សី វារីវប្បកម្ម ឬការនេសាទប៉ុណ្ណោះ។ ម៉្យាងវិញទៀត វាក៏អាចជាការកាន់កាប់ដែលមានសកម្មភាពទាំងនេះបញ្ចូលគ្នាផងដែរ។ ការកាន់កាប់កសិកម្មពីរក្រុមធំៗនៅកម្ពុជាគឺ៖ ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ។ ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ អាចជាកម្មសិទ្ធិរបស់បុគ្គលម្នាក់ ឬគ្រប់គ្រងដោយបុគ្គលម្នាក់ ឬដោយមនុស្សមួយក្រុម។ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គឺជាអង្គភាព

កសិកម្មដែលគ្រប់គ្រង និងដំណើរការដោយសហគ្រាសរដ្ឋ ឬឯកជន ខ. សាជីវកម្មកសិកម្ម ភាពជាដៃគូ សហគមន៍ ស្ថាប័នឯកជនស្ថាប័នរដ្ឋាភិបាល។ល។

## ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ

ភាគច្រើននៃការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ គឺជាការកាន់កាប់ដែលមានតែក្នុងបរិវេណលំនៅស្ថាន។ សកម្មភាព នៃការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា ត្រូវបានបំបែកជាពីរក្រុម៖ សកម្មភាពកសិកម្មតែក្នុងបរិវេណលំនៅស្ថាន ឬសកម្មភាពកសិកម្មក្នុងបរិវេណលំនៅស្ថាន និងនៅលើក្បាលដីដាច់ដោយឡែកផងដែរ។ ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានចំនួនសរុប ២.០៣៨.០០០ គ្រួសារ។

**តារាងទី២.១. ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ ដែលមានក្បាលដី និងដីជុំវិញបរិវេណលំនៅស្ថាន**

| ប្រទេសកម្ពុជា | | |
|---|---|---|
| ចំនួនគ្រួសារកសិកម្ម (000) | ចំនួនកាន់កាប់ដែលមានតែដីជុំវិញបរិវេណលំនៅស្ថាន (000) | ការកាន់កាប់កសិកម្មដែលមានទាំងក្បាលដីនិងដីជុំវិញបរិវេណលំនៅស្ថាន (000) |
| 2.038 | 278 | 1.761 |

៩៧,៧% នៃការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារសរុបនៅកម្ពុជា ត្រូវបានរាយការណ៍ថា ធ្វើឡើងក្រោមរូបភាពជាម្ចាស់កម្មសិទ្ធិ ឬ ជាភោគី លើផ្នែកខ្លះនៃការកាន់កាប់កសិកម្មនោះ។ មានតែ ៤,៨% នៃការកាន់កាប់ទាំងនេះ ដែលត្រូវបានរាយការណ៍ថាស្ថិតក្រោមការជួលដីកសិកម្មពីគ្រួសារផ្សេងទៀត។

**តារាងទី២.២. ការប្រើប្រាស់ដីកសិកម្មដោយគ្រួសារដែលជាអ្នកកាន់កាប់**

| ប្រទេសកម្ពុជា | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំនួនគ្រួសារកសិកម្មសរុប (000) | ជាម្ចាស់កម្មសិទ្ធិ/ភាគី | | ជួលពីគ្រួសារដទៃ | | ប្រើប្រាស់ដោយឥតគិតថ្លៃ | | ការកាន់កាប់ផ្សេងទៀត | |
| | ចំនួនកាន់កាប់ (000) | % នៃការកាន់កាប់ | ចំនួនកាន់កាប់ (000) | % នៃការកាន់កាប់ | ចំនួនកាន់កាប់ (000) | % នៃការកាន់កាប់ | ចំនួនកាន់កាប់ (000) | % នៃការកាន់កាប់ |
| 2.038 | 1.991 | 98 | 98 | 5 | 31 | 2 | 7 | 0,3 |

គ្រួសារកសិកម្មនៅកម្ពុជា បានផលិតកសិផលសម្រាប់គោលបំណងផ្សេងៗជាច្រើនដូចជា ការប្រើប្រាស់ក្នុងគ្រួសារ និងសម្រាប់លក់។ ដូចដែលបានបង្ហាញក្នុងរូបខាងក្រោម នៅពេលសួរអំពីគោលដៅនៃផលិតកម្មកសិកម្មពីការកាន់កាប់ ចម្លើយជាទូទៅច្រើនបំផុតគឺសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។

រូបទី២.១. គោលបំណងចម្បងនៃផលិតកម្មកសិកម្មនៃគ្រួសារកសិកម្ម




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ

ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គឺជាអង្គភាពដែលគ្រប់គ្រង និងដំណើរការដោយសហគ្រាសឯកជន ឬរដ្ឋ រួមទាំងសាជីវកម្ម ភាពជាដៃគូ សហគមន៍ ស្ថាប័នឯកជន ស្ថាប័នរដ្ឋាភិបាល។ល។ ក្នុងអំឡុងនៃដំណើរការអង្កេតកសិកម្មឆ្នាំ២០២០ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំចំនួន ១៩៧ ត្រូវបានកំណត់ថា បានចូលរួមក្នុងសកម្មភាពកសិកម្ម ដែលរួមមាន ការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី និងការធ្វើវារីវប្បកម្ម។ ចំនួននៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលបានរាយការណ៍ មានតិចតួចណាស់ ដែលអាចបណ្តាលពីវិសាលភាពតូចនៃខ្ទង់សំណាក ដែលបានរៀបចំឡើងសម្រាប់ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំនៅក្នុងអំឡុងពេលនៃការអង្កេតនេះ។ ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋបាលជលផល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានផ្តល់បញ្ជីអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ និងព័ត៌មានលម្អិតសម្រាប់ការទាក់ទង។ អ្នកប្រមូលទិន្នន័យ បានព្យាយាមទាក់ទងអ្នកកាន់កាប់កសិកម្មគិតិយុត្តិទាំងអស់នៅក្នុងបញ្ជី ដែល រួមទាំង ចុះដល់ទីតាំងផ្ទាល់នៅតាមខេត្ត និងតាមអាសយដ្ឋានដែលបានចុះឈ្មោះក្នុងរាជធានីភ្នំពេញផងដែរ។ ក្នុងករណីខ្លះ ការព្យាយាមទាក់ទងអ្នកកាន់កាប់ដែលបានចុះបញ្ជីមិនទទួលជោគជ័យទេ ហើយក្នុងករណីផ្សេងទៀត មានការរកឃើញថា នៅលើដីកាន់កាប់សហគ្រាសកសិកម្មខ្នាតធំខ្លះ ពុំមានសកម្មភាពកសិកម្មឡើយ។

ជំពូកទី៩ នៃរបាយការណ៍នេះផ្តោតទៅលើទិន្នន័យដែលទទួលបានពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ដែលបានសម្ភាស។ ជំពូកទី៣ ដល់ទី៨ ខាងក្រោម ផ្តោតលើការកាន់កាប់កសិកម្មជាគ្រួសារតែប៉ុណ្ណោះ។

# ជំពូកទី៣៖ ផលិតកម្មដំណាំ

សកម្មភាពចម្បងដែលធ្វើឡើងដោយការកាន់កាប់កសិកម្មជាគ្រួសារនៅកម្ពុជា គឺការដាំដំណាំ និងការប្រមូលផលដំណាំបណ្ដោះអាសន្ន និងអចិន្ត្រៃយ៍។ ក្នុងចំណោមការកាន់កាប់កសិកម្មសរុបចំនួន ២,០៤ លានគ្រួសារ ការកាន់កាប់កសិកម្មចំនួន ១,៩ លានគ្រួសារ បានរាយការណ៍ពីការដាំដំណាំ។

ដំណាំបណ្ដោះអាសន្ន គឺជាដំណាំដែលមានវដ្ដលូតលាស់តិចជាងមួយឆ្នាំ ហើយក្រោយពេលប្រមូលផល ត្រូវបានសាបព្រោះឡើងវិញ ឬដាំឡើងវិញ សម្រាប់វដ្ដផលិតកម្មផ្សេងទៀត។ ដំណាំបណ្ដោះអាសន្នដែលបង្ហាញក្នុង CAS គឺជាដំណាំដែលត្រូវបានដាំតាមរដូវកាលក្នុងអំឡុងពេលយោង និងស្ថិតក្នុងចំណាត់ថ្នាក់ដំណាំសំខាន់ៗចំនួន ១៤ក្រុម ដែលរួមមានធញ្ញជាតិ និងស្រូវ ដំណាំគ្រាប់ ដំណាំគ្រាប់យកប្រេង ដំណាំផ្ដល់មើម គ្រឿងទេស គ្រឿងផ្ដល់រសជាតិបន្លែម រុក្ខជាតិក្រអូប និងរុក្ខជាតិឱសថ ដំណាំឧស្សាហកម្ម និងបន្លែជាច្រើនមុខ។

ដំណាំអចិន្ត្រៃយ៍ ជាដំណាំដែលមានវដ្ដលូតលាស់លើសពីមួយឆ្នាំ និងដែលកំពុងមានវត្តមាន និងផ្ដល់ផលនៅក្រោមការកាន់កាប់កសិកម្ម។ ដំណាំទាំងនេះ ត្រូវបានចាត់ថ្នាក់ជា ១១ក្រុមធំៗ ដែលបានប្រើក្នុងការកំណត់អត្តសញ្ញាណដំណាំអចិន្ត្រៃយ៍ផ្សេងៗគ្នា ដែលរួមមាន ដំណាំហូបផ្លែ ដំណាំផ្ដល់គ្រាប់ ដំណាំប្រេង កៅស៊ូ គ្រឿងទេស និងគ្រឿងក្រអូប និងដំណាំផ្សេងទៀតដែលមិនប្រើប្រាស់ជាអាហារ។ ដំណាំអចិន្ត្រៃយ៍ជាច្រើន ត្រូវការពេលវេលា ដើម្បីលូតលាស់ មុននឹងអាចផ្ដល់ផលជាលើកដំបូង។ ដូចនេះសម្រាប់ដំណាំខ្លះផ្ទៃដីប្រមូលផលអាចតូចជាងផ្ទៃដីដំណាំ ព្រោះថាដំណាំទាំងនេះពុំទាន់ដល់អាយុផ្ដល់ផលនៅឡើយ។

ដោយសារមានដំណាំជាច្រើនមុខដែលដាំនៅកម្ពុជា និងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយបន្ទុកលើអ្នកឆ្លើយ និងរយៈពេលសម្ភាសន៍ ដូច្នេះទិន្នន័យលម្អិតត្រូវបានប្រមូលសម្រាប់តែដំណាំសំខាន់ជាងគេ ៣០មុខប៉ុណ្ណោះ ទៅតាមការកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សម្រាប់ដំណាំទាំង ៣០មុខនេះ អ្នកឆ្លើយបានផ្ដល់ព័ត៌មានដែលទាក់ទងនឹងផ្ទៃដីដំណាំ ផ្ទៃដីប្រមូលផល បរិមាណផលប្រមូលបាន ការប្រើប្រាស់ជី ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ការស្រោចស្រព និងភាគចំណែកនៃផលិតផល ទាំងសម្រាប់លក់ ឬទុកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ដើម្បីកាត់បន្ថយបន្ទុកមកលើអ្នកឆ្លើយ ទិន្នន័យសម្រាប់ដំណាំអចិន្ត្រៃយ៍ត្រូវបាន គិតជាហិកតា ឬ ចំនួនដើម ដោយផ្អែកលើការនិយមរបស់អ្នកឆ្លើយ។ ដូចនេះ ទិន្នន័យដែលបានរាយការណ៍ជាចំនួនដើម ត្រូវបានបំប្លែងទៅជាហិកតា ដោយផ្អែកលើមេគុណបំប្លែង ដែលផ្ដល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឧបសម្ព័ន្ធទី១)។

ប្រការសំខាន់គឺ អ្នកប្រើប្រាស់ទិន្នន័យត្រូវកត់សម្គាល់ថា នីតិវិធីដែលបានប្រើនៅក្នុង អង្កេតកសិកម្មឆ្នាំ២០២០ ខុសប្លែកពីនីតិវិធីដែលបានប្រើនៅក្នុងកិច្ចប្រឹងប្រែងវាយតម្លៃកសិកម្មផ្សេងទៀតនៅកម្ពុជា។ អង្កេតកសិកម្មឆ្នាំ២០២០ ជាការអង្កេតសំណាកប្រហាក់ប្រហែល ដែលនីតិវិធីនេះបានផ្អែកលើទិន្នន័យបានពីស្វ័យរាយការណ៍ នៅកម្រិតនៃការកាន់កាប់កសិកម្ម សម្រាប់អំឡុងពេលយោងជាក់លាក់ចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២០ ដែលក្នុងនោះការកាន់កាប់កសិកម្មមិនមែនគ្រួសារនៅក្នុងការអង្កេតនេះ មានត្រឹមកម្រិតកំណត់ប៉ុណ្ណោះ។ ជាលទ្ធផលផ្ទៃដីសរុប បរិមាណផលិតផល និងទិន្នផលដែលបានគណនា សម្រាប់ដំណាំនានា អាចខុសគ្នាពីប្រភពទិន្នន័យផ្សេងទៀត។

រូបទី ៣.១. ចំនួនគ្រួសារកសិកម្មដែលរាយការណ៍អំពីដំណាំឆ្នាំ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំធញ្ញជាតិ និងធញ្ញជាតិយកគ្រាប់

ដំណាំសំខាន់ៗចំនួនពីរមុខ ដែលដាំនៅកម្ពុជាគឺ ស្រូវ និងពោត។ ពូជស្រូវដែលដាំ មានដូចជា ស្រូវធម្មតា ស្រូវក្រអូប និងស្រូវដំណើប។ ពោតត្រូវបានគេចាត់ជាពូជ ពោតស/លឿង/ស្វាយ។

ក្នុងចំណោមស្រូវទាំងបីបែប មកទល់ពេលនេះ មានការដាំស្រូវពូជធម្មតាទូទៅជាងគេ ដោយផ្ទៃដីដាំមានទំហំប្រមាណ ១,៩៨លានហិកតា និងផ្ទៃដីប្រមូលផលប្រមាណ ១,៨៩លានហិកតា។ ទិន្នផលជាមធ្យមក្នុងមួយហិកតានៃពូជស្រូវធម្មតា ត្រូវបានប៉ាន់ប្រមាណថាមាន ២.៥៣២ គីឡូក្រាម ដោយបរិមាណផលសរុបដែលប្រមូលបាននៅកម្ពុជា មានប្រមាណ ៤.៦៨ លានតោន។ តំបន់បឹងទន្លេសាបជាកន្លែងដែលមានដំណាំស្រូវធម្មតាច្រើនជាងគេ លើផ្ទៃដីទំហំ ៩០៤.០០០ ហិកតា ចំណែកតំបន់ ទំនាបមានដំណាំស្រូវលើផ្ទៃដីទំហំ ៨០៤.០០០ ហិកតា។

រូបទី ៣.២. ផ្ទៃដីដំណាំស្រូវធម្មតាចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

ពូជស្រូវក្រអូប មានដាំលើផ្ទៃដីប្រមាណ ៧០១ ពាន់ហិកតា ក្នុងប្រទេសកម្ពុជា ដោយមានផ្ទៃដីប្រមូលផលទំហំ ៦៤២ ពាន់ហិកតា។ ទិន្នផលជាមធ្យមក្នុងមួយហិកតានៃពូជស្រូវក្រអូប មានប្រមាណ ២.២៣៩ គីឡូក្រាម ហើយមានបរិមាណផលសរុបដែលប្រមូលបាននៅកម្ពុជា មានប្រមាណ ១.២ លានតោន។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

ស្រូវដំណើប ពុំមានដាំច្រើនដូចស្រូវធម្មតា និងស្រូវក្រអូបឡើយ ដោយមានផ្ទៃដីដាំ និងផ្ទៃដីប្រមូលផលត្រឹម ៦.០០០ ហិកតាប៉ុណ្ណោះ។ ទិន្នផលជាមធ្យមនៃពូជស្រូវដំណើប ត្រូវបានប៉ាន់ប្រមាណថាមាន ២.២៤១ គីឡូក្រាមក្នុងមួយហិកតា ដោយបរិមាណផលសរុបដែលប្រមូលបាននៅកម្ពុជា មានប្រមាណ ១១ ពាន់តោន។

ពោតត្រូវបានដាំនៅលើផ្ទៃដីទំហំ ៩៧ ពាន់ហិកតា នៅទូទាំងប្រទេសកម្ពុជា ដោយតំបន់បឹងទន្លេសាបមានដំណាំពោតប្រមាណ ៨០ ពាន់ហិកតា ដែលជាតំបន់នាំមុខគេលើផ្ទៃដីដាំពោត។ ទិន្នផលពោតជាមធ្យម មានប្រមាណ ៤.៨៩១ គីឡូក្រាមក្នុងមួយហិកតានៃ ដោយបរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ៤១០ ពាន់តោន។

## ដំណាំយកមើម

ដំណាំផ្តល់មើម មានដូចជា ដំឡូងមី ដំឡូងជ្វា ត្រាវ សាគូ និងប៉ិគក់។ ផ្ទៃដីដាំដំឡូងមីមានទំហំធំបំផុត និងមានទំហំ ៤០២ ពាន់ហិកតា និងផ្ទៃដីប្រមូលផល ៣១៩ពាន់ហិកតា។ ទិន្នផលដំឡូងមីជាមធ្យម មានប្រមាណ ១២.០៩០ គីឡូក្រាមក្នុងមួយហិកតា ដោយបរិមាណផលដែលប្រមូលបានសរុប មានប្រមាណ ៣,៧ លានតោន។

រូបទី៣.៤. ដំឡូងមី ចំនួនគ្រួសារដែលរាយការណ៍តាមតំបន់




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំពពួកសណ្តែកយកគ្រាប់

រុក្ខជាតិផ្តល់គ្រាប់ មានដូចជា សណ្តែកបាយ គឺជាប្រភពប្រូតេអ៊ីនដ៏សំខាន់។ ដំណាំសណ្តែកនៅកម្ពុជា មានដាំលើផ្ទៃដីប្រមាណ ១១.០០០ ហិកតា ដោយមានផ្ទៃដីប្រមូលផល ១០.០០០ ហិកតា។ បរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ១១.០០០ តោន។

## ដំណាំប្រភេទគ្រាប់យកប្រេង

ការអង្កេត CAS បានប្រមូលទិន្នន័យអំពីដំណាំគ្រាប់ផ្តល់ប្រេង ដូចជា សណ្តែកដី ល្ង សណ្តែកសៀង និងល្ហុងប្រេង។ ផ្ទៃដីដំណាំ និងផ្ទៃដីប្រមូលផលល្ងសរុបនៅកម្ពុជា មានប្រមាណ ៦.០០០ ហិកតា ដោយបរិមាណផលសរុបមានប្រមាណ ៣.០០០ តោន។ សណ្តែកសៀងត្រូវបានដាំលើផ្ទៃដី ១៦.០០០ ហិកតា និងផ្ទៃដីប្រមូលផល ១៥.០០០ ហិកតា។ សណ្តែកដីមានដាំ និងប្រមូលផលលើផ្ទៃដីសរុប ១.០០០ ហិកតា ដោយផ្តល់ផលសរុប ៤.០០០ តោន។

## រុក្ខជាតិជាគ្រឿងទេស គ្រឿងក្រអូប រុក្ខជាតិឱសថ

ព័ត៌មានដែលប្រមូលបានអំពីគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិឱសថក្នុងការអង្កេតកសិកម្ម រួមមាន ស្លឹកគ្រៃ ជីអង្កាម និងរមៀត។ គ្រួសារដែលរាយការណ៍ពីការដាំស្លឹកគ្រៃត្រូវបានប៉ាន់ប្រមាណថាមាន ២៦៦ ពាន់គ្រួសារ ហើយ ៦៤ ពាន់គ្រួសារដាំជីអង្កាម និង ១៦ ពាន់គ្រួសារដាំរមៀត។ ផ្ទៃដីដាំម្រេចសរុប ត្រូវបានប៉ាន់ប្រមាណថាមាន ១២.០០០ ហិកតា និងផ្ទៃដីប្រមូលផល ១១.០០០ ហិកតា។ បរិមាណផលម្រេច ត្រូវបានប៉ាន់ប្រមាណថាមាន ២៣.០០០ តោន។ តំបន់ទំនាប មានផ្ទៃដីដាំដំណាំធំជាងគេ ពោលគឺ ៨.០០០ ហិកតា បន្ទាប់មកតំបន់ភ្នំ និងខ្ពង់រាប ដែលមានផ្ទៃដីដាំដំណាំទំហំ ២.០០០ ហិកតា។

## ដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្មនៅក្រោមការអង្កេតកសិកម្ម រួមមាន អំពៅ។ ផ្ទៃដីដាំអំពៅសរុបនៅកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមាន ៤.០០០ ហិកតា ផ្ទៃដីប្រមូលផលបាន ៣.០០០ ហិកតា និងផ្តល់ផលសរុបប្រមាណ ៦០ ពាន់តោន។ តំបន់វាលទំនាប និងតំបន់បឹងទន្លេសាប មានផ្ទៃដីដាំអំពៅប្រមាណ ២.០០០ ហិកតា ក្នុងតំបន់នីមួយៗ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំបន្លែ

បន្លែជាច្រើនមុខត្រូវបានដាំនៅទូទាំងប្រទេស ដូចជា បន្លែស្លឹក ដើម និងផ្លែ មើម បន្លែបៃតង។ល។ រុក្ខជាតិបន្លែដែលផ្តល់ផ្លែ នៅក្នុងការអង្កេតកសិកម្ម នេះមានដូចជា ម្ទេស ត្រសក់ ត្រប់ ស្លឹកបាស ល្ពៅ ម្ទេសប្លោក ននោង និងត្រឡាច។ បន្លែស្លឹក ឬដើម មានដូចជា ផ្ទី ខ្ទឹមស្លឹក និងត្រកួន។

នៅកម្ពុជា ត្រសក់ត្រូវបានដាំដោយកសិករប្រមាណ ៣៣ ពាន់គ្រួសារ លើផ្ទៃដីដំណាំ និងផ្ទៃដីប្រមូលផលប្រមាណ ៦.០០០ហិកតា។ ផលិតផលត្រសក់សរុបមាន ៥៤.០០០ តោន។

នៅកម្ពុជា ម្ទេសត្រូវបានដាំដុះដោយកសិករប្រមាណ ៦០.០០០ គ្រួសារ លើផ្ទៃដីដាំ និងផ្ទៃដីប្រមូលផលប្រមាណ ១.០០០ ហិកតា។ បរិមាណផលសរុបដែលទទួលបាន មានប្រមាណ ៥ ពាន់តោន។

នៅកម្ពុជា កសិករប្រមាណ ១៦ពាន់គ្រួសារ បានដាំល្ពៅ។ កសិករប្រមាណ ៣៧ពាន់គ្រួសារ ដាំត្រប់។ ប៉េងប៉ោះត្រូវបានដាំដុះដោយកសិករប្រមាណ ៤.០០០គ្រួសារ។ នៅកម្ពុជា សណ្តែកកួរ ត្រូវបានដាំដោយកសិករប្រមាណ ប្រមាណ ១៤ ពាន់គ្រួសារ លើផ្ទៃដីដាំ និងផ្ទៃដីប្រមូលផល ប្រមាណ ១.០០០ ហិកតា។

## ដំណាំហូបផ្លែ

ដំណាំក្រូច ត្រូវបានរកឃើញថាមានច្រើននៅកម្ពុជា ហើយដំណាំដែលស្ថិតក្នុងការអង្កេតកសិកម្មនេះមានដូចជា ក្រូចថ្លុង ក្រូចឆ្មា និងក្រូចពោធិ៍សាត់។ ការអង្កេតកសិកម្ម បានប្រមូលទិន្នន័យអំពីផ្ទៃដីដំណាំអចិន្ត្រៃយ៍ ដោយគិតទាំងជា ហិកតា ឬ ជាចំនួនដើមឈើ តាមការនិយមរបស់អ្នកឆ្លើយ។ ដើម្បីឱ្យទិន្នន័យមានភាពស៊ីសង្វាក់គ្នា របាយការណ៍ជាចំនួនដើមឈើត្រូវបានបំប្លែងទៅជាហិកតា ដោយប្រើមេគុណបំប្លែងដែលផ្តល់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអត្រាទាំងនេះមានក្នុងឧបសម្ព័ន្ធទី១ នៃរបាយការណ៍នេះ។

កសិករប្រមាណ ៥.០០០ គ្រួសារនៅកម្ពុជា ដាំឳឡឹក។ ល្ហុងត្រូវបានដាំដោយកសិករប្រមាណ ១៦៦.០០០ គ្រួសារក្នុងប្រទេសកម្ពុជា។ កសិករប្រមាណ ៥៤ ពាន់គ្រួសារក្នុងប្រទេសកម្ពុជា ដាំក្រូចពោធិសាត់។ ផ្ទៃដីដាំក្រូចមានប្រមាណ ៨ ពាន់ហិកតា។ កសិករប្រមាណ ២០.០០០ គ្រួសារ បានដាំម្នាស់។

កសិករប្រមាណ ៩៣៧ ពាន់គ្រួសារក្នុងប្រទេសកម្ពុជា ដាំស្វាយ។ ផ្ទៃដីដាំស្វាយមានប្រមាណ ១៣៨.០០ ហិកតា ក្នុងនោះ មានតែ ៧៦ ហិកតា ដែលបានប្រមូលផល។ បរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ៥៥៤,០០០ តោន។



រូបទី ៣.៦. ស្វាយ ចំនួនគ្រួសារដែលរាយការណ៍តាមតំបន់

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

កសិករប្រមាណ ២៦៥.០០០ គ្រួសារ បានដាំខ្នុរ។ ផ្ទៃដីដាំខ្នុរមានប្រមាណ ៤.០០០ ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលមានប្រមាណ ២.០០០ ហិកតា។ បរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ១៤.០០០ តោន។




រូបទី ៣.៧. ខ្នុរ ចំនួនគ្រួសារដែលរាយការណ៍គិតតាមតំបន់ ឆ្នាំ២០២០

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

កសិករប្រមាណ ២២.០០០ គ្រួសារ បានដាំទុរេន។ ផ្ទៃដីដាំទុរេន មានប្រមាណ ៩.០០០ ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលមានប្រមាណ ៣.០០០ ហិកតា។ បរិមាណផលសរុបដែលប្រមូលបាន គឺប្រមាណ ១៧.០០០ តោន។




រូបទី៣.៨. ផ្ទៃដីដាំទុរេន គិតជាហិកតា តាមតំបន់ ឆ្នាំ២០២០

*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

ដំណាំយកផ្លែជាច្រើនបែប មានដាំនៅប្រទេសកម្ពុជា ហើយការអង្កេតកសិកម្មនេះ បានប្រមូលទិន្នន័យអំពីដំណាំ ចេក ទៀប ស្រកានាគ ទុរេន ត្របែក ខ្នុរ ពុទ្រា មៀន ផ្លែស្វាយ ផ្លែទឹកដោះ ល្ហុង ម្នាស់ ល្មុត ទៀបបារាំង និងខ្ទិះ។ ក្នុងចំណោមដំណាំទាំងនេះ ស្វាយមានដាំលើផ្ទៃដីដាំធំជាងគេ ដែលមានប្រមាណ ១៣៨.០០០ ហិកតា។

ចេកត្រូវបានដាំនៅទូទាំងប្រទេសកម្ពុជាលើផ្ទៃដីទំហំ ២៦.០០០ ហិកតា ដោយមានផ្ទៃដីប្រមូលផល ១៦.០០០ ហិកតា។ បរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ៩០ ពាន់តោន។ តំបន់បឹងទន្លេសាបជាកន្លែងដែលមានផ្ទៃដីដាំចេកធំ ជាងគេ ដោយមានផ្ទៃដីដាំទំហំ ១០.០០០ ហិកតា។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំស្វាយចន្ទី

ក្នុងចំណោមរុក្ខជាតិដែលផ្តល់គ្រាប់សម្រាប់បរិភោគ ការអង្កេតកសិកម្មនេះបានប្រមូលទិន្នន័យអំពីស្លា និងស្វាយចន្ទី ក្នុងនោះគ្រាប់ស្វាយចន្ទីមានការពេញនិយមជាងគេ។ កសិករប្រមាណ ២៣៦ ពាន់គ្រួសារ នៅកម្ពុជា ដាំស្វាយចន្ទី។ ផ្ទៃដីដាំស្វាយចន្ទីត្រូវបានប៉ាន់ប្រមាណថាមាន ៤៨៧.០០០ ហិកតា ផ្ទៃដីប្រមូលផល ២៨៥.០០០ ហិកតា និងបរិមាណផលសរុបមានប្រមាណ ២០០.០០០ តោន។ តំបន់ខ្ពង់រាប និងតំបន់ភ្នំ ត្រូវបានរាយការណ៍ថា មានផ្ទៃដីដំណាំគ្រាប់ស្វាយចន្ទីធំជាងគេ ដោយមានទំហំ ២៤៤.០០០ ហិកតា។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំយកប្រេង

ដំណាំប្រេងដែលស្ថិតក្រោមការអង្កេតកសិកម្មនេះរួមមាន ដូង និងត្នោត ។ ដូង ជាដំណាំពេញនិយមជាងគេក្នុងចំណោមដំណាំទាំងពីរនេះ ដែលកសិករ ៦៥២ ពាន់គ្រួសារ បានរាយការណ៍ថា បានដាំដូង។ ផ្ទៃដីដាំដូងត្រូវបានគេប៉ាន់ប្រមាណថាមានទំហំ ២៣.០០០ ហិកតា និងផ្ទៃដីប្រមូលផល ប្រមាណ ៧.០០០ ហិកតា។ បរិមាណផលសរុបប្រមូលបានមានប្រមាណ៧៨.០០០ តោន។ តំបន់បឹងទន្លេសាបមានផ្ទៃដីដាំដូងធំជាងគេ ដែលមានទំហំ ៣.០០០ ហិកតា។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ដំណាំគ្រឿងទេស និងគ្រឿងក្រអូប

កសិករប្រមាណ ១៩ពាន់គ្រួសារ បានដាំម្រេច។ ផ្ទៃដីដាំម្រេច មានទំហំប្រមាណ ១២.០០០ ហិកតា និងផ្ទៃដីប្រមូលផលប្រមាណ ១១.០០០ ហិកតា។ បរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ២៣.០០០ តោន។ តំបន់វាលទំនាបបានរាយការណ៍ថា មានផ្ទៃដីដាំម្រេចធំជាងគេ ពោលគឺ ៨.០០០ ហិកតា បន្ទាប់មក តំបន់ខ្ពង់រាប និងតំបន់ភ្នំដែលមានផ្ទៃដីដាំ ២.០០០ ហិកតា។

## ដំណាំកៅស៊ូ

កសិករប្រមាណ ៤៩ ពាន់គ្រួសារនៅកម្ពុជា បានដាំកៅស៊ូ។ ផ្ទៃដីដាំកៅស៊ូមានប្រមាណ ១៣០.០០០ ហិកតា ក្នុងនោះផ្ទៃដីប្រមូលផលប្រមាណ ១០៩.០០០ហិកតា។ បរិមាណផលកៅស៊ូសរុប មានប្រមាណ ៥១៤.០០០ តោន។ តំបន់ទំនាប មានផ្ទៃដីដាំកៅស៊ូធំជាងគេ ដែលមានទំហំ ៧៦ ពាន់ហិកតា។

## ដំណាំមិនមែនអាហារ

ឫស្សី ដែលប្រើប្រាស់សម្រាប់ពហុបំណង ដែលរួមទាំង សម្រាប់សាងសង់ផ្ទះ គ្រឿងសង្ហារិម និងការចម្អិនអាហារ គឺជាដំណាំមិនមែនអាហារនាំមុខគេ ដែលមានកសិករប្រមាណ ៤៥.០០០ គ្រួសារដែលត្រូវបានរាយការណ៍ថា បានដាំឫស្សី។ តំបន់វាលទំនាប ត្រូវបានរាយការណ៍ថា មានចំនួនគ្រួសារដាំឫស្សីច្រើនជាងគេ ដល់ ១៧ ពាន់គ្រួសារ។

## ការប្រើប្រាស់ជី សារធាតុគីមី និងប្រព័ន្ធស្រោចស្រព

ការប្រើប្រាស់ជី សារធាតុគីមី និងប្រព័ន្ធស្រោចស្រពនៅកម្ពុជា មានលក្ខណៈខុសគ្នាទៅតាមមុខដំណាំដែលដាំ ដូចមានបង្ហាញខាងក្រោម។ អ្នកឆ្លើយ ត្រូវបានសួរតាមមុខដំណាំថា តើមានការប្រើជី ថ្នាំសម្លាប់សត្វល្អិតលើដំណាំ ឬ មានប្រើប្រព័ន្ធធារាសាស្រ្តដែរឬទេ។ ជីបានដែលប្រើប្រាស់ មានដូចជា ជីសរីរាង្គ និងអសរីរាង្គ។ ច្រើនជាង ៩០ ភាគរយនៃគ្រួសារដែលដាំស្រូវក្រអូប បានប្រើជីលើដំណាំស្រូវក្រអូបរបស់ខ្លួន។ ប្រមាណ ៨៦ ភាគរយនៃគ្រួសារដែលដាំស្រូវធម្មតា បានប្រើជីលើដំណាំស្រូវរបស់ខ្លួន។

រូបទី៣.១២. ភាគរយគ្រួសារកសិកម្មដែលប្រើជី/ថ្នាំកំចាត់សត្វចង្រៃ/ប្រព័ន្ធធារាសាស្រ្ត នៅកម្ពុជា ឆ្នាំ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

# ជំពូកទី៤ ៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី

ការចិញ្ចឹមបសុសត្វ និងបសុបក្សីនៅកម្ពុជា ជាសកម្មភាពកសិកម្មដ៏សំខាន់មួយ ដែលធ្វើឡើងដោយគ្រួសារកសិកម្ម និងដើរតួនាទីជាគន្លឹះក្នុងការគាំទ្រជីវភាព និងផ្តល់ប្រាក់ចំណូលដល់គ្រួសារនៅជនបទ។ ក្នុងចំណោមការកាន់កាប់កសិកម្មសរុបចំនួន ២.០៣៨.០០០ គ្រួសារនៅកម្ពុជា ការកាន់កាប់ចំនួន ១.៦៧០.០០០ គ្រួសារ ឬត្រូវជា ៨២% បានចិញ្ចឹមបសុសត្វ និង/ឬបសុបក្សីនៅពេលនៃប្រមូលទិន្នន័យសម្រាប់អង្កេតកសិកម្មកម្ពុជា។

**តារាងទី៤.១. ចំនួននៃការកាន់កាប់កសិកម្មជាគ្រួសារដែលមានសកម្មភាពផលិតកម្មបសុសត្វ គិតជាពាន់**

| ប្រទេសកម្ពុជា | | | | |
|---|---|---|---|---|
| ចិញ្ចឹមបសុសត្វធំ (គោ ក្របី សេះ) | ចិញ្ចឹមបសុសត្វតូច (ជ្រូក ពពែ) | បក្សី ( មាន់ ទា ត្រចៀកកាំ។ល។ ) | ផ្សេងទៀត (សត្វល្អិត ។ល។) | ចំនួនកាន់កាប់ដែលមានការចិញ្ចឹមបសុសត្វ/បសុបក្សី/សត្វល្អិត |
| ចំនួនកាន់កាប់ (000) | | | | |
| ៨០៨ | ១១០ | ១.៥៣៥ | ២ | ១.៦៧០ |

ចំនួនគ្រួសារដែលចិញ្ចឹមបសុសត្វ និងបសុបក្សីច្រើនជាងគេ ត្រូវបានរកឃើញនៅក្នុងតំបន់ទំនាប (៨០%នៃគ្រួសារកសិកម្ម) បន្ទាប់មកគឺ តំបន់បឹងទន្លេសាប (៨២%នៃគ្រួសារកសិកម្ម) តំបន់ខ្ពង់រាប និងតំបន់ភ្នំ (៨៣%នៃគ្រួសារកសិកម្ម) និងតំបន់ឆ្នេរ (៩២%នៃគ្រួសារកសិកម្ម) ។

រូបទី៤.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ បសុបក្សី តាមតំបន់




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

នៅប្រទេសកម្ពុជា មានការចិញ្ចឹមបសុសត្វចំនួនពីរក្រុមធំៗ ដែលត្រូវបានដាក់បញ្ចូលក្នុងការអង្កេតកសិកម្ម ។ បសុសត្វទាំងនោះរួមមាន បសុសត្វធំៗ ដូចជា គោ ក្របី សេះ និងបសុសត្វតូចៗ ដូចជា ជ្រូក និងពពែ។ ចិតសិបប្រាំភាគរយនៃការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស បានរាយការណ៍ពីការចិញ្ចឹមបសុបក្សី ក្នុងនោះ ៤០% រាយការណ៍ពីការចិញ្ចឹមបសុបក្សីធំ និង ៥% រាយការណ៍ពីការចិញ្ចឹមបសុបក្សីតូចៗ។ គ្រួសារជាច្រើនបានរក្សាទុកទាំងបសុសត្វ និងបសុបក្សី។ ក្នុងករណីចិញ្ចឹមគោ គ្រួសារ ៩៣% ចិញ្ចឹមពី ១ ទៅ ៩ ក្បាល។ ក្នុងករណី ចិញ្ចឹមក្របី គ្រួសារ ៩៤% ចិញ្ចឹមពី ១ ទៅ ៩ ក្បាល។ ក្នុងករណីចិញ្ចឹម បសុបក្សី គ្រួសារ ៩២% បានរាយការណ៍ពីសត្វស្លាបពី ១ ទៅ ៩៩ក្បាល។ មានតែ ០,៤% នៃគ្រួសារចិញ្ចឹមបសុបក្សី ដែលបានរាយការណ៍ថា ចិញ្ចឹមចំនួន ៥០០ក្បាល ឬច្រើនជាងនេះ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## បសុសត្វធំ

### គោ

នៅក្នុងការអង្កេតកសិកម្មបសុសត្វធំៗរួមមាន សេះ គោ និងក្របី។ បសុសត្វធំដែលមានចិញ្ចឹមទូទៅជាងគេក្នុងគ្រួសារកសិកម្មគឺ គោ ដោយចំនួនគោ មានជិត៩ដង ច្រើនជាងក្របី។ ដោយមានគោសរុបប្រមាណ ៣,២ លានក្បាលនៅទូទាំងប្រទេស ចំនួនមធ្យមនៃគោក្នុងមួយគ្រួសារមានប្រមាណ ៤,៤ ក្បាល ។ តំបន់វាលទំនាបមាន ៣៩% នៃចំនួនសត្វគោសរុបនៅក្នុងប្រទេស (១.២៧១.០០០ ក្បាល) បន្ទាប់មកតំបន់បឹងទន្លេសាបមាន ៣២% (១.០៣៩.០០០ក្បាល) តំបន់ភ្នំ និងខ្ពង់រាបមាន ២៣% (៧៥០.០០០ ក្បាល) និង តំបន់ឆ្នេរដែលមាន ៦% (១៨៧.០០០ក្បាល)។ ចំនួនគោដែលចិញ្ចឹមតាមគ្រួសារនីមួយៗនៅកម្ពុជាមានខុសគ្នា ក្នុងនោះ ៥៣% នៃការកាន់កាប់កសិកម្មជាគ្រួសារ បានរាយការណ៍ថាមាន ពី ៣ ទៅ ៩ ក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

នៅក្នុងប្រទេសកម្ពុជា សត្វគោត្រូវបានចិញ្ចឹមក្នុងបំណងជាច្រើន មានដូចជា ការចិញ្ចឹមសម្រាប់លក់ និងចិញ្ចឹមសម្រាប់បង្កាត់ពូជ។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## ក្របី

ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស បានរាយការណ៍ថាមានសត្វក្របីសរុបចំនួន ៣៥៨.០០០ ក្បាល ដោយ ៤២% ស្ថិតនៅក្នុងតំបន់បឹងទន្លេសាប (១៥២.០០០ ក្បាល) បន្ទាប់មក ៣១% ស្ថិតនៅក្នុងតំបន់វាលទំនាប

(១១១.០០០ក្បាល) ២០% នៅតំបន់ភ្នំ និងខ្ពង់រាប (៧៣.០០០ក្បាល) និង ៦%នៅតំបន់ឆ្នេរសមុទ្រ (២២.០០០ក្បាល)។ ចំនួនក្របីដែលចិញ្ចឹមតាមគ្រួសារនៅកម្ពុជាមានខុសៗគ្នា ក្នុងនោះ ៥៩% នៃគ្រួសារបានរាយការណ៍ថាបានចិញ្ចឹមពី ៣ ទៅ ៩ ក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

នៅក្នុងប្រទេសកម្ពុជា ការចិញ្ចឹមក្របីធ្វើឡើង ក្នុងបំណងជាច្រើន ដោយបំណងសំខាន់មានដូចជា ការចិញ្ចឹមសម្រាប់លក់ និងការចិញ្ចឹមសម្រាប់បង្កាត់ពូជ ។

រូបទី៤.៨. ចំនួនក្របីនៃគ្រួសារកសិកម្ម តាមគោលដៅនៃការចិញ្ចឹម




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## បសុសត្វតូច

ចំនួនជ្រូកចិញ្ចឹមតាមគ្រួសារនៅទូទាំងប្រទេសកម្ពុជា មាន ៩៨៧.០០០ ក្បាល ។ គ្រួសារកសិកម្មនៅតំបន់បឹងទន្លេសាបបានរាយការណ៍ពីការចិញ្ចឹមជ្រូករហូតដល់ ៣០% (៣០១.០០០ ក្បាល) នៃចំនួនជ្រូកទាំងអស់នៅកម្ពុជា ដោយតំបន់ខ្ពង់រាប និងតំបន់ភ្នំចិញ្ចឹមបាន ១៥% (១៤៨.000ក្បាល)។ ជ្រូកភាគច្រើនត្រូវបានចិញ្ចឹមសម្រាប់លក់ទាំងរស់ ហើយសត្វជ្រូកជាច្រើនក៏ត្រូវបានរក្សាទុកសម្រាប់បង្កាត់ពូជផងដែរ។ ជ្រូកចិញ្ចឹមតាមគ្រួសារក្នុងប្រទេសកម្ពុជាមានចំនួនខុសគ្នា ក្នុងនោះ ៧២% នៃគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ថាមានចិញ្ចឹមពី ១ ទៅ៩ ក្បាល។

រូបទី៤.៩. ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ពីការចិញ្ចឹមជ្រូក នៅក្នុងអំឡុងឆ្នាំយោង គិតតាមតំបន់ ឆ្នាំ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

រូបទី៤.១០. ចំនួនគ្រួសារកសិកម្ម តាមចំនួនជ្រូកដែលបានចិញ្ចឹម




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

នៅក្នុងប្រទេសកម្ពុជា ជ្រូកត្រូវបានចិញ្ចឹមក្នុងគោលបំណងជាច្រើន ដោយគោលបំណងសំខាន់រួមមានដូចជា ការចិញ្ចឹមសម្រាប់លក់ទាំងរស់ និងសម្រាប់គោលបំណងបង្កាត់ពូជ។

រូបទី៤.១១. ចំនួនជ្រូកចិញ្ចឹមដោយគ្រួសារកសិកម្ម តាមគោលបំណងនៃការចិញ្ចឹម




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## បសុបក្សី

មាន់ និងទា គឺជាបសុបក្សី ដែលត្រូវបានចិញ្ចឹមជាទូទៅច្រើនបំផុតដោយគ្រួសារកសិកម្ម ដោយមានមាន់ចំនួនប្រមាណ ៤៧,៧ លានក្បាល និងទា ១៥,៣ លានក្បាល ត្រូវបានរាយការណ៍ដោយគ្រួសារកាន់កាប់កសិកម្មនៅថ្ងៃប្រមូលទិន្នន័យ។ តំបន់ទំនាបបានរាយការណ៍ថាមានបសុបក្សីច្រើនជាង ២៦លានក្បាល ហើយតំបន់បឹងទន្លេសាបបានរាយការណ៍ថា មានបសុបក្សីច្រើនជាង ២៣ លានក្បាល ដែលរួមមាន មាន់ ទា និងក្ងាន។ ភាគច្រើននៃគ្រួសារកាន់កាប់កសិកម្មដែលបានរាយការណ៍

ពីបសុបក្សី បានចិញ្ចឹមពី ១ ទៅ ៩៩ក្បាល ដោយ ១៧%នៃគ្រួសារកាន់កាប់កសិកម្ម រាយការណ៍ថាបានចិញ្ចឹមពី ១ ទៅ ៩ ក្បាល និង ៧៥%បានរាយការណ៍ពីការចិញ្ចឹមពី ១០ ទៅ ៩៩ក្បាល។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

# ជំពូកទី៥ ៖ វារីវប្បកម្ម និងការនេសាទ

សកម្មភាពវារីវប្បកម្ម និងការនេសាទ ជាសកម្មភាពសេដ្ឋកិច្ចជំនួសឬបន្ថែម សម្រាប់គ្រួសារកសិកម្មនៅកម្ពុជា។ យោងតាមការអង្កេតកសិកម្ម មានការប៉ាន់ប្រមាណថា អ្នកកាន់កាប់កសិកម្មចំនួន ១២៥.000 គ្រួសារ បានធ្វើវារីវប្បកម្ម ចំណែកអ្នកកាន់កាប់ កសិកម្មចំនួន ៥៥៤.000 គ្រួសារ បានចូលរួមក្នុងសកម្មភាពនេសាទ។ មានអ្នកកាន់កាប់កសិកម្មចំនួន ៤២.000 គ្រួសារ ដែលចូលរួមទាំងក្នុងសកម្មភាពវារីវប្បកម្ម និងនេសាទ។ តំបន់ដែលមានចំនួនគ្រួសារភាគច្រើនពាក់ព័ន្ធក្នុងវារីវប្បកម្មគឺ តំបន់ទំនាប ដែលមាន ៨២.000គ្រួសារ ដែលរាយការណ៍ពីសកម្មភាពវារីវប្បកម្ម។ តំបន់ដែលមានចំនួនគ្រួសារច្រើនជាងគេ ក្នុងសកម្មភាពនេសាទគឺ តំបន់បឹងទន្លេសាបដែលមានអ្នកកាន់កាប់កសិកម្មចំនួន ២៥១.000 គ្រួសារដែលរាយការណ៍ពីសកម្មភាពនេសាទ។

## ការនេសាទ

អង្កេតកសិកម្មឆ្នាំ២០២០ សកម្មភាពនេសាទត្រូវបានបែងចែកតាមប្រភេទទឹកសាប (ទន្លេ ឬបឹង) ទឹកសមុទ្រ ទឹកភ្លាវ ឬតាមវាលស្រែ។ សកម្មភាពនេសាទនេះ រួមមាន ការនេសាទត្រី និងវារីសត្វដទៃទៀតក្នុងសមុទ្រ តំបន់ឆ្នេរ និងក្នុងដែនទឹកសាបនានា ដោយមាន ឬគ្មានការប្រើប្រាស់ទូក ឬឧបករណ៍នេសាទឯកទេស។ ការនេសាទនេះ រួមបញ្ចូល ការនេសាទនៅពេលណាមួយក្នុងអំឡុងពេលយោងនៃ អង្កេតកសិកម្មឆ្នាំ២០២០ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០។

រូបទី ៥.១. ផលត្រីនៅក្នុងការនេសាទ ចំនួនគ្រួសារកសិកម្មដែលពាក់ព័ន្ធគិតតាមប្រភេទ សកម្មភាពនេសាទ កម្ពុជា ឆ្នាំ ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

**រូបទី៥.២. ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពនេសាទតាមតំបន់**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

អង្កេតកសិកម្មឆ្នាំ២០២០ បានប្រមូលទិន្នន័យអំពីវារីជាតិជាច្រើនប្រភេទដែលបាននេសាទរួមមាន ត្រី បង្កងទឹកសាប ក្តាម ខ្យង អន្ទង់ បង្គា ឬបង្គាជើងស និងវារីជាតិដទៃទៀត។ ខណៈពេលដែល ៩៨% នៃគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីសកម្មភាពនេសាទត្រី ២៤% បាននេសាទក្តាម និង ១៣% នេសាទខ្យង។ ផលនេសាទសរុប ត្រូវបានរាយការណ៍ថាមាន ៨៦,៤ លានគីឡូក្រាម។ អ្នកឆ្លើយត្រូវបានស្នើឱ្យពន្យល់ពីសកម្មភាពនេសាទចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ធៀបនឹងសកម្មភាពកាលពីឆ្នាំមុន។ យោងតាមទិន្នន័យនេះ ៣៩% នៃគ្រួសារកសិកម្មដែលបានរាយការណ៍ពីសកម្មភាពនេសាទបានបញ្ជាក់ថា ផលនេសាទសម្រាប់ឆ្នាំ ២០១៩/២០២០ មានទាបជាងផលចាប់កាលពីឆ្នាំមុន។ ១៤% នៃគ្រួសារកសិកម្មបានរាយការណ៍ថា ផលចាប់បានកើនច្រើនជាងឆ្នាំមុន ហើយ ៤៧% បានរាយការណ៍ថា ផលចាប់ មានប្រហែលនឹងឆ្នាំមុន។ នៅកម្រិតជាតិ សម្រាប់គ្រួសារកសិកម្មដែលរាយការណ៍ពីសកម្មភាពនេសាទ ៨៥% នៃផលចាប់ ត្រូវបានប៉ាន់ប្រមាណថា បានប្រើប្រាស់សម្រាប់ការបរិភោគក្នុងគ្រួសារ។

**រូបទី៥.៣. ការប្រៀបធៀបរវាងផលនេសាទក្នុងឆ្នាំបច្ចុប្បន្ន ទៅឆ្នាំមុន នៃគ្រួសារកសិកម្ម**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

## វារីវប្បកម្ម

វារីវប្បកម្ម សំដៅលើវប្បកម្មវារីសត្វនៅក្នុងសមុទ្រ បឹង ទន្លេ និងតំបន់វាលទំនាប ឬ ដែនទឹកផ្សេងទៀត ដូចជាក្នុង ស្រះ វាលស្រែ ឬតំបន់ផ្សេងទៀត នៅក្រោមលក្ខខណ្ឌគ្រប់គ្រង។ ក្នុងចំណោមសកម្មភាពខុសៗគ្នានៃវារីវប្បកម្មដែលបានប្រមូលទិន្នន័យ នៅក្នុងការអង្កេតតកសិកម្មឆ្នាំ២០២០ ការធ្វើវារីវប្បកម្មប្រព្រឹត្តទៅនៅក្នុងស្រះ ស៊ង បែរ វាលស្រែ បំពង់លូ/អាង/ធុង អាងភ្ញាស់/អាងបំប៉ន ឬ សកម្មភាពផ្សេងទៀតនៃវារីវប្បកម្ម ដែលក្នុងនោះសកម្មភាពទូទៅជាងគេ ធ្វើឡើងនៅក្នុងស្រះ ដោយ ១០១.០០០ គ្រួសារកសិកម្ម។ ប្រមាណ ៧.០០០ គ្រួសារកសិកម្ម បានធ្វើវារីវប្បកម្មក្នុងបែរ ហើយ ១៧.០០០ គ្រួសារ បានចូលរួមនៅក្នុងសកម្មភាពវប្បកម្ម ក្នុងបំពង់លូ អាង ឬ ធុង។

ផ្ទៃដីសរុបដែលបានប្រើសម្រាប់តែវារីវប្បកម្ម ពីសំណាក់គ្រួសារកាន់កាប់ក្បាលដីកសិកម្ម មានប្រមាណ ៣.០៧៧ ហិកតា និង ១.៥២៩ ហិកតា ជាសកម្មភាពធ្វើឡើងនៅក្នុងបរិវេណលំនៅស្ថាន។ តំបន់ទំនាប មានផ្ទៃដីបរិវេណលំនៅស្ថានធំជាងគេដែលបានប្រើសម្រាប់វារីវប្បកម្ម ដោយផ្ទៃដីបរិវេណលំនៅស្ថានទំហំ៩៤៨ ហិកតា ត្រូវបានប្រើប្រាស់សកម្មភាពវារីវប្បកម្ម។ ចំពោះប្រភេទនៅក្នុងវារីវប្បកម្ម ប្រភេទដែលសម្បូរបំផុតដែលបានរាយការណ៍នៅថ្ងៃសម្ភាសន៍ អង្កេតកសិកម្ម រួមមាន ត្រីប្រាធំ (១០៦.៩ លានក្បាល) ត្រីអណ្តែង (៤៥.៤ លានក្បាល) និងត្រីឆ្តោ (២៤.៨ លានក្បាល)។

**រូបទី៥.៤. ចំនួនគ្រួសារកសិកម្មដែលរាយការណ៍សកម្មភាពវារីវប្បកម្ម ចែកតាមតំបន់**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

# ជំពូកទី៦៖ សកម្មភាពសេដ្ឋកិច្ចបន្ថែមនៅក្នុងគ្រួសារកសិកម្ម

គ្រួសារកសិកម្មនៅកម្ពុជា បានបំពេញបន្ថែមសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួន ទាំងនៅក្រោមការគ្រប់គ្រងរបស់ខ្លួន តាមរយៈសកម្មភាពដែលទាក់ទងនឹងព្រៃឈើ សិប្បកម្ម អាជីវកម្មខ្នាតតូច និងសកម្មភាពនៅក្រៅការកាន់កាប់របស់ខ្លួន ដោយធ្វើការនៅក្នុងដីកសិកម្មផ្សេងទៀតនិងការងារនានាក្នុងវិស័យសេវាកម្ម។ ក្នុងចំណោមការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារប្រមាណ១៣៦,% នៃគ្រួសារទាំងនេះ បានរាយការណ៍ពីការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចបន្ថែមខ្លះៗមួយចំនួន។ សកម្មភាពទាំងនេះរួមមាន ការកែច្នៃដំឡូងមី កិនស្រូវ ឬធញ្ញជាតិ ការផលិតស្ករត្នោត ការកែច្នៃសាច់ ឬត្រី និងការផលិតវត្ថុសិប្បកម្ម។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

បើយើងក្រឡេកមើលទៅលើការរាយការណ៍របស់គ្រួសារកសិកម្ម ដែលបានធ្វើការឲ្យគ្រួសារដទៃដោយប្រើប្រាស់សម្ភារៈរបស់គាត់ដែលមាន ដើម្បីរកចំណូលគឺមានរហូតដល់ ៦០% នៃអ្នកកាន់កាប់ទាំងនោះបានរាយការណ៍ពីការរួមចំណែកនៃការងារនេះយ៉ាងច្រើន ចំពោះប្រាក់ចំណូលសរុបរបស់ខ្លួន។ លើសពីនេះទៀត ក្នុងចំណោមគ្រួសារកសិកម្មដែលធ្វើការឱ្យអ្នកការកាន់កាប់កសិកម្មផ្សេងទៀត ៥៥% រាយការណ៍ថា បរិមាណប្រាក់ចំណូលដែលបានមកតាមរយៈការងារបែបនេះ មានប្រហែលគ្នា នឹងឆ្នាំមុន ១០% រាយការណ៍ថា ប្រាក់ចំណូលបែបនេះ មានច្រើនជាងឆ្នាំមុន និង ៣៥% ពោលថា ប្រាក់ចំណូលបានមកតាមរបៀបនេះ មានទាបជាងឆ្នាំមុន។

រូបទី ៦.២. ភាគចំណែកនៃប្រាក់ចំណូលដែលបានពីធ្វើការឱ្យអ្នកដទៃ នៅក្នុងប្រាក់ចំណូលសរុបប្រចាំគ្រួសារ




រូបទី ៦.៣. ភាពចំណែកនៃប្រាក់ចំណូលដែលបានពីធ្វើការឱ្យអ្នកដទៃ ធៀបនឹងឆ្នាំមុន




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

រូបទី ៦.៤. ចំនួនគ្រួសារកសិកម្ម ដែលពាក់ព័ន្ធក្នុងការផលិតវត្ថុសិប្បកម្ម តាមតំបន់




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

អ្នកកាន់កាប់កសិកម្មប្រហែល ៣១.០០០ គ្រួសារ បានរាយការណ៍ពីការចូលរួមក្នុងការងារសិប្បកម្ម ដូចជា ត្បាញកន្ត្រក និងកន្ទេល ការផលិតអំបោះ និងសម្ភារៈសម្រាប់ផលិតសំលៀកបំពាក់។ គ្រួសារដែលប្រកបរបរសិប្បកម្មក្នុងចំនួនច្រើនជាងគេ ត្រូវបានរកឃើញនៅក្នុងតំបន់វាលទំនាប និងតំបន់បឹងទន្លេសាប។

ក្នុងចំណោមការកាន់កាប់កសិកម្មសរុបចំនួន ២.០៣៨ លានគ្រួសារ នៅក្នុងប្រទេសកម្ពុជា ២៣% បានចូលរួមក្នុងសកម្មភាពព្រៃឈើ ដូចជា រកអុស (ជីវម៉ាសឈើដែលផ្តល់ថាមពល - ផ្តល់កំដៅ ការចម្អិនអាហារ)។ គ្រួសារចូលរួមក្នុងសកម្មភាពព្រៃឈើផ្សេងទៀត រួមមាន កាប់ឈើ រកទំពាំង និងផ្សិត បរបាញ់សត្វ ផលិតធ្យូង និងរកផលអនុផលព្រៃឈើ ដូចជា ផ្តៅ វល្លិ អំបោសស្លឹកត្នោត ស្បូវ ជាដើម។

**រូបទី ៦.៥. ចំនួនគ្រួសារកសិកម្មដែលពាក់ព័ន្ធនឹងសកម្មភាពព្រៃឈើ តាមតំបន់**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

អ្នកឆ្លើយសំណួរនៅក្នុងការអង្កេតកសិកម្មឆ្នាំ២០២០ បង្ហាញពីចំណែកនៃប្រាក់ចំណូលប្រចាំគ្រួសាររបស់ខ្លួន ដែលត្រូវបានគណនាជាប្រាក់ចំណូលពីកសិកម្មរបស់ពួកគាត់។ ដូចដែលអាចឃើញនៅក្នុងរូបខាងក្រោម សម្រាប់គ្រួសារកសិកម្មភាគច្រើននៅកម្ពុជា ក្នុងចំណោមប្រមាណពាក់កណ្ដាល ឬតិចជាងនេះនៃប្រាក់ចំណូលសរុប ត្រូវបានគណនាថា ជាប្រាក់ចំណូលប្រចាំគ្រួសារដែលបានមកពីកសិកម្ម។ ដូចគ្នានេះផងដែរ អ្នកឆ្លើយបានពន្យល់ពីប្រាក់ចំណូលពីកសិកម្មរបស់ខ្លួនសម្រាប់រយៈពេល ១២ ខែចុងក្រោយ ធៀបនឹងប្រាក់ចំណូលរបស់ពួកគាត់សម្រាប់ឆ្នាំមុន។ ក្នុងចំណោម ៥៦ %នៃការកាន់កាប់កសិកម្ម ប្រាក់ចំណូលពីកសិកម្មនាពេលថ្មីៗរបស់ពួកគាត់ ត្រូវបានប៉ាន់ប្រមាណថា មានប្រហែលនឹងឆ្នាំមុន ខណៈដែល ១១% បានរាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មមានខ្ពស់ជាងឆ្នាំមុន ហើយ ៣៤% រាយការណ៍ថា ប្រាក់ចំណូលពីកសិកម្មមានទាបជាងឆ្នាំមុន។

**រូបទី ៦.៦. ចំនួនគ្រួសារកសិកម្ម គិតតាមភាគចំណែកនៃប្រាក់ចំណូលសរុប ដែលចាត់ទុកថាបានពីសកម្មភាពកសិកម្ម គិតតាមតំបន់ ឆ្នាំ ២០២០**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

**រូបទី ៦.៧. ចំនួនគ្រួសារកសិកម្ម គិតតាមភាគចំណែកនៃប្រាក់ចំណូលសរុបប្រចាំគ្រួសារ ធៀបនឹងឆ្នាំមុន តាមតំបន់ ឆ្នាំ ២០២០**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

ប្រមាណ ៤០% នៃគ្រួសារកសិកម្មបានរាយការណ៍ថា បានរងគ្រោះធ្ងន់ធរក្នុងរយៈពេល ១២ ខែចុងក្រោយ បណ្តាលពីព្រឹត្តិការណ៍អាកាសធាតុដូចជា ព្យុះទីហ្វុង ទឹកជំនន់ ការបាក់ដី ឬគ្រោះរាំងស្ងួត និងឧប្បទ្ទវហេតុផ្សេងទៀត ដែលរួមទាំងសត្វល្អិតបំផ្លាញដំណាំ ដំណាំមានជំងឺ ឬបសុសត្វមានជំងឺ។ អ្វីដែលថ្មីសម្រាប់ការអង្កេតកសិកម្មឆ្នាំ២០២០ គឺការស្រង់យកផលប៉ះពាល់ដែលអាចកើតមាន បណ្តាលពីជំងឺរាតត្បាតជាសកលនៃកូវីដ១៩ មកលើវិស័យកសិកម្មនៅកម្ពុជា។ រូបខាងក្រោមបង្ហាញបញ្ហានានា ដែលត្រូវបានរាយការណ៍ថាជួបប្រទះជាទូទៅបំផុត និងត្រូវបានចាត់ទុកថា បង្កការប៉ះទង្គិចធ្ងន់ធ្ងរបំផុត (ក្នុងចំណោមការប៉ះទង្គិចធ្ងន់ធ្ងរបំផុតចំនួន៣) ដែលរាយការណ៍ដោយអ្នកកាន់កាប់កសិកម្ម ដែលរួមមាន គ្រោះរាំងស្ងួត ទឹកជំនន់ វិបត្តិកូវីដ១៩ និងការរាតត្បាតនៃសត្វល្អិត ព្រមទាំង អត្រាប្រេវ៉ាឡង់នៃបញ្ហាទាំងនេះនៅទូទាំងប្រទេសកម្ពុជា។ ការឆ្លើយតបជាទូទៅចំពោះការប៉ះទង្គិចទាំងនេះរួមមាន ការមិនធ្វើអ្វីសោះ ការលក់ផលដំណាំ និង/ឬបសុសត្វ ការស្វែងរកការងារនៅក្រៅការកាន់កាប់កសិកម្ម ឬការចងការប្រាក់។

**រូបទី ៦.៨. ការទទួលរងគ្រោះហានីភ័យធ្ងន់ធ្ងរ (គ្រួសារដែលរាយការណ៍ថា ទទួលរងគ្រោះហានីភ័យយ៉ាងហោចមួយ) គិតតាមចំនួនគ្រួសារកសិកម្មដែលរាយការណ៍ឆ្នាំ២០២០**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

នៅកម្រិតជាតិ ការកាន់កាប់កសិកម្មប្រមាណ ២៤៩.០០០ គ្រួសារ បានរាយការណ៍ថា កូវីដ១៩ ស្ថិតក្នុងចំណោមការប៉ះទង្គិចធ្ងន់ធ្ងរបំផុតចំនួនបី មកលើការកាន់កាប់កសិកម្មរបស់ពួកគាត់ ឬរាយការណ៍ថា សកម្មភាពកសិកម្មរបស់ពួកគាត់បានរងការប៉ះទង្គិចតាមរូបភាពផ្សេងៗដោយសារវិបត្តិកូវីដ១៩ ចាប់តាំងពីខែមីនា ឆ្នាំ ២០២០មក។ ក្នុងចំណោមគ្រួសារដែលរាយការណ៍អំពីផលប៉ះពាល់បណ្តាលពីរោគរាតត្បាត មកលើសកម្មភាពរបស់ខ្លួន ២០៨.០០០ គ្រួសារ បានរាយការណ៍ពីផលប៉ះពាល់មកលើសកម្មភាពដាំដំណាំរបស់ពួកគាត់។ ផលប៉ះពាល់ទាំងនេះត្រូវបានរាយការណ៍ថា មានឥទ្ធិពល ទាំងមកលើកសិផលរបស់អ្នកកាន់កាប់ ក៏ដូចជា មកលើការលក់កសិផលផងដែរ។ ក្នុងចំណោមការកាន់កាប់ ១៧៤.០០០ គ្រួសារ ដែលរាយការណ៍ពីផលប៉ះពាល់ចំពោះផលិតកម្មដំណាំរបស់ពួកគាត់ ៥៩% បានរាយការណ៍ពីការថយចុះនៃផលិតកម្មដំណាំរបស់ខ្លួនដោយសារតែវិបត្តិកូវីដ១៩។ ក្នុងចំណោមការកាន់កាប់ ១៧២.០០០ គ្រួសារ ដែលរាយការណ៍ពីផលប៉ះពាល់មកលើការលក់ផលដំណាំរបស់ខ្លួន ៧២% បានរាយការណ៍ពីការថយចុះនៃការលក់ដំណាំរបស់ខ្លួន ដោយសារតែវិបត្តិកូវីដ១៩។

នៅពេលពិនិត្យមើលអ្នកកាន់កាប់ទាំងអស់ដែលបានរាយការណ៍ពីការប៉ះទង្គិចបែបណាមួយក្នុងអំឡុងពេលយោង អ្នកឆ្លើយបានពោលអំពីថាតើអ្នកកាន់កាប់បានធូរស្រាលពីការប៉ះទង្គិចធ្ងន់ធ្ងរបំផុតឬទេ និងថាតើឥឡូវនេះ អ្នកកាន់កាប់អាចទប់ទល់នឹងការប៉ះទង្គិចធ្ងន់ធ្ងរបំផុតបានល្អជាងមុនឬទេ។ នៅកម្ពុជា ប្រមាណ ៦៣% នៃអ្នកកាន់កាប់ដែលរាយការណ៍ពីការប៉ះទង្គិច បានបញ្ជាក់ថា ពួកគាត់មិនបានធូរស្រាលទាំងស្រុងពីការប៉ះទង្គិចធ្ងន់ធ្ងរបំផុតឡើយ (មិនរាប់បញ្ចូល ជំងឺកូវីដ១៩)។ ប្រមាណ ៧៥% នៃចំនួនអ្នកកាន់កាប់កសិកម្ម ដែលរាយការណ៍ពីការប៉ះទង្គិច បានពោលថា ឥឡូវនេះពួកគាត់ពុំមានលក្ខណៈងាយស្រួលជាងមុនក្នុងការទប់ទល់នឹងការប៉ះទង្គិចធ្ងន់ធ្ងរបំផុតទាំងនោះទេ។

## ជំពូកទី៧ ៖ គ្រួសារកសិកម្ម និងស្ថានភាពប្រជាសាស្ត្រ

គ្រួសារកាន់កាប់កសិកម្ម នៅទូទាំងប្រទេសកម្ពុជា មានចំនួនសមាជិកខុសៗគ្នា ដោយភាគច្រើននៃគ្រួសារកសិកម្មមានសមាជិកពី ៤ ទៅ៥នាក់។ ប្រមាណ ៤៨% នៃគ្រួសារកសិកម្មមានសមាជិកពី ៤ ទៅ ៥នាក់ និង ៣០% មានពី ២ ទៅ ៣នាក់។

**រូបទី ៧.១. ចំនួនគ្រួសារកាន់កាប់កសិកម្ម និងចំនួនសមាជិកក្នុងគ្រួសារ តាមតំបន់ ឆ្នាំ ២០២០**




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

បុរស និងស្ត្រីដែលមានអាយុចន្លោះពី ៤៥ ទៅ ៦៤ ឆ្នាំ គឺជាក្រុមមនុស្សដែលមានចំនួនច្រើនជាងគេ (ប្រហែល ៤៩%) នៃមនុស្សទាំងអស់ដែលរស់នៅក្នុងគ្រួសារកាន់កាប់កសិកម្ម បន្ទាប់មកគឺក្រុមអាយុពី ២៥ ទៅ៤៤ឆ្នាំ (ប្រហែល ៨%)។ អាស្រ័យលើក្រុមអាយុខុសៗគ្នា ស្ត្រីមានចំនួនច្រើនជាងបុរស ចាប់ពី ២ ទៅ ១០% នៅទូទាំងក្រុមអាយុផ្សេងៗគ្នា។ ក្នុងចំណោមសមាជិកគ្រួសារកាន់កាប់កសិកម្ម ក្រុមមនុស្សដែលមានអាយុពី ២៥ ទៅ ៤៤ ឆ្នាំ គឺជាក្រុមធំជាងគេ (ប្រមាណ ២៩%)។ សម្រាប់គ្រួសារកាន់កាប់កសិកម្មទាំងអស់ សមាមាត្រនៃសមាជិកជាស្ត្រី ធៀបនឹងបុរសនៅក្នុងគ្រួសារ មានពី ៥១% ទៅ ៤៩% ដែលបង្ហាញពីវត្តមានរបស់សមាជិកជាស្ត្រី ច្រើនជាងសមាជិកជាបុរស។




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

សមាជិកគ្រួសារម្នាក់ៗ ដែលមានអាយុលើសពី ៥ ឆ្នាំ ត្រូវបានរកឃើញថា មានការសិក្សាកម្រិតខ្ពស់បំផុត។ ប្រមាណ ១៣% នៃសមាជិកគ្រួសារដែលមានអាយុចាប់ពី ៥ ឆ្នាំឡើងទៅ ពុំបានចូលសិក្សាឡើយ ដោយ ៦% នៃសមាជិកគ្រួសារទាំងនេះបានបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យ (ថ្នាក់ទី ១២)។ សមាជិកគ្រួសារចំនួន ៣% បានទទួលសញ្ញាបត្រមធ្យមសិក្សាបច្ចេកទេស ឬសញ្ញាបត្រកម្រិតសាកលវិទ្យាល័យ។ ចាប់ពីថ្នាក់ទី ៤ ឡើងទៅ សមាមាត្រនារីនៅក្នុងការសិក្សា មានទាបជាងបុរស នៅក្នុងកម្រិតសិក្សាដូចគ្នា។ ឧទាហរណ៍ បុរសចំនួន ៣% បានបញ្ចប់ការសិក្សាថ្នាក់ទី ១២ ដោយតួលេខនេះ មានត្រឹមតែ ២% ប៉ុណ្ណោះសម្រាប់នារី ។ ក្នុងចំណោមសមាជិកគ្រួសារដែលមានអាយុចាប់ពី ៥ ឆ្នាំ ដល់ ២៤ ឆ្នាំ សមាជិកទាំងនេះ ៦២% បានរាយការណ៍ថា ពុំបានចូលរៀនក្នុងឆ្នាំសិក្សាបច្ចុប្បន្ននេះឡើយ។ សមាជិកគ្រួសារដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ត្រូវបានសួរថាតើពួកគាត់បានទទួលការបណ្តុះបណ្តាលផ្លូវការណាមួយអំពីកសិកម្មឬទេ។ ក្នុងចំណោមសមាជិកគ្រួសារទាំងនោះ ស្ត្រី ៩២% និងបុរស ៩០% បានទទួលការបណ្តុះបណ្តាលជាផ្លូវការអំពីកសិកម្ម។ ដូចគ្នានេះផងដែរ សម្រាប់សមាជិកគ្រួសារដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ស្ត្រី ៤១% និងបុរស ៣៩% បានរាយការណ៍ថា បានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលរួមទាំង ការសម្រេចចិត្តទាក់ទងនឹងដំណាំសម្រាប់ដាំ និងបសុសត្វសម្រាប់ចិញ្ចឹម លើដីកសិកម្មដែលខ្លួនកាន់កាប់។

សមាជិកគ្រួសារកសិកម្មប្រមាណ ៧០% ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ បានរៀបការ ដោយមាន ៨% ជាស្ត្រីមេម៉ាយ ១% បានលែងលះគ្នា ឬរស់នៅបែកគ្នា និង ២១% ពុំទាន់រៀបការ ហើយពុំមានដៃគូរស់នៅជាមួយឡើយ។ អត្រាស្ត្រី

មេម៉ាយ មានខ្ពស់ជាងបុរសពោះម៉ាយ (១២% ធៀបនឹង ៣%) ហើយ អត្រាស្ត្រីដែលបានលែងលះគ្នា ឬរស់នៅបែកគ្នា ក៏ខ្ពស់ជាងបុរសផងដែរ (១% សម្រាប់ស្ត្រី ធៀបនឹង តិចជាង ១% សម្រាប់បុរស)។

នៅក្នុង CAS ២០២០ ក៏មានការប្រមូលទិន្នន័យបន្ថែមផងដែរ ដើម្បីវាយតម្លៃអំពីសិទ្ធិប្រើប្រាស់ដីកសិកម្ម ដោយសមាជិកគ្រួសារដែលមានអាយុលើសពី ១៥ ឆ្នាំ។ ក្នុងចំណោមសមាជិកគ្រួសារទាំងនេះ បច្ចុប្បន្ន បុរស ៦១% និង ស្ត្រី ៦២% កំពុងប្រើប្រាស់ កាន់កាប់ ឬ រក្សាសិទ្ធិប្រើប្រាស់លើដីកសិកម្មណាមួយតែម្នាក់ឯង ឬ រួមគ្នា ជាមួយបុគ្គលណាម្នាក់ផ្សេងទៀត។ សមាជិកគ្រួសារទាំងនេះ ៨១% មានឯកសារដែលបញ្ជាក់ពីកម្មសិទ្ធិ ឬ សិទ្ធិប្រើប្រាស់ដីកសិកម្មនៅក្នុងការកាន់កាប់នោះ។ សមាជិកគ្រួសារទាំងនេះមានឯកសារបែបនេះ ដែលអាចជា បង្កាន់ដៃទទួលពាក្យសុំ (សម្រាប់ ៤១% នៃសមាជិកគ្រួសារ) វិញ្ញាបនបត្រ/ប័ណ្ណកម្មសិទ្ធិដីចេញដោយរដ្ឋាភិបាល (សម្រាប់ ៣១% នៃសមាជិកគ្រួសារ) ឬ ឯកសារពីអាជ្ញាធរមូលដ្ឋាន (សម្រាប់ ២៨% នៃសមាជិកគ្រួសារ)។ ក្នុងចំណោមទាំងបុរស និងស្ត្រីដែលជាសមាជិកមានសិទ្ធិប្រើប្រាស់ សមាជិក ៩៩,៧% បានចុះឈ្មោះតែម្នាក់ឯង ឬ រួមគ្នាជាមួយនរណាម្នាក់ផ្សេងទៀត នៅលើឯកសារទាំងនេះ សមាជិក ៩៥,៧% មានសិទ្ធិលក់ដីកសិកម្មដោយឯកឯង ឬ សិទ្ធិរួមជាមួយអ្នកដទៃណាម្នាក់ផ្សេង ហើយ សមាជិក ៩៤,៤% មានសិទ្ធិផ្ទេរដីកសិកម្មណាមួយដោយឯកឯង ឬ រួមគ្នាជាមួយអ្នកដទៃណាម្នាក់ សម្រាប់ការបន្តជាមរតក។

## ជំពូកទី៨ ៖ កម្លាំងពលកម្មចូលរួមក្នុងសកម្មភាពកសិកម្ម

កម្លាំងពលកម្មនៅលើដីកសិកម្មណាមួយ បានមកពីប្រភពជាច្រើន ដែលរួមទាំង សមាជិកគ្រួសារកាន់កាប់កសិកម្មនោះ (អាយុចាប់ពី ៥ ឆ្នាំឡើងទៅ) កម្មកររម្លងម្ដាល ដែលបានជួយក្នុងការជាក់លាក់ណាមួយ ឬកម្មករដែលជួលមកពីក្រៅ។ ទិន្នន័យអំពីកម្លាំងពលកម្ម ត្រូវបានប្រមូលយក ដោយគិតតាមភេទ ប្រភេទកម្មករ និងញែកដាច់គ្នាទៅតាមកិច្ចការចំបងៗផងដែរ ដែលរួមមាន ការដាំដំណាំ ការចិញ្ចឹមបសុសត្វ ឬ វារីវប្បកម្ម ឬ សកម្មភាពនេសាទ។

រូបទី ៨.១. សមាជិកគ្រួសារដែលធ្វើការលើដីកាន់កាប់ដោយគ្រួសារដទៃ កម្ពុជា ឆ្នាំ ២០២០




រូបទី ៨.២. ចំនួនឯកត្តាពេលវេលាគិតជាមធ្យម ដែលសមាជិកគ្រួសារបានធ្វើការ នៅក្នុងអំឡុងឆ្នាំយោង កម្ពុជា ឆ្នាំ ២០២០




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០*

ក្នុងចំណោមសមាជិកគ្រួសារកាន់កាប់កសិកម្ម សមាជិកជាបុរសចំនួន ៦៩% និង ស្ត្រី ៦៦% បានពោលថា ខ្លួនធ្វើការនៅលើដីកសិកម្មដែលគ្រួសារខ្លួនកាន់កាប់។ សមាជិកជាបុរស បានធ្វើការជាមធ្យម ៦៥១ ម៉ោង នៅលើដីកាន់កាប់នោះនៅក្នុងឆ្នាំនេះ ធៀបនឹងស្ត្រីដែលមានត្រឹម ៥២២ ម៉ោងជាមធ្យម។

អ្នកកាន់កាប់កសិកម្មជាគ្រួសារប្រមាណ១% បានរាយការណ៍ពីការប្រើប្រាស់កម្លាំងពលកម្ម ដែលជាអ្នកបានទទួលប្រាក់ឈ្នួល ឬ ពុំបានប្រាក់ឈ្នួល ដែលមិនមែនជាសមាជិកគ្រួសារកាន់កាប់កសិកម្មនោះ។ អ្នកទាំងនោះ មានទាំង កម្មករពេញម៉ោង ឬមិនពេញម៉ោងផងដែរ។ ក្រៅពីនេះ មានការជួលកម្មករម្តងម្កាល ឱ្យបំពេញកិច្ចការជាក់លាក់ណាមួយ លើដីកសិកម្មនោះ។ កិច្ចការទាំងនេះ មានជាអាទិ៍ ការដាំដំណាំ ការច្រូតកាត់ បោកស្រូវ ជាដើម។ គ្រួសារកសិកម្ម ២៤% បានរាយការណ៍ពីការប្រើប្រាស់កម្មករម្តងម្កាល ដែលមាន ៤៧% គឺជាបុរសនិង ៥៣%ជាស្ត្រី។ ការផលិតដំណាំ គឺជាសកម្មភាពទូទៅបំផុតសម្រាប់កម្មករម្តងម្កាល។

**តារាងទី៨.១. ចំនួនកម្មករក្នុងការងារកសិកម្ម ក្នុងផ្នែកគ្រួសារកសិកម្ម គិតតាមប្រភេទកម្មករ នៅកម្រិតតំបន់ ឆ្នាំ២០២០**

| កម្រិតថ្នាក់ជាតិ/តំបន់ | ប្រភេទកម្មករនៅក្នុងការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ | | |
|---|---|---|---|
| | សមាជិកគ្រួសារ | កម្មករពីក្រៅ | ចំនួនកម្មករសរុប |
| | ចំនួនកម្មករ (000) | | |
| ប្រទេសកម្ពុជា | 5408 | 44 | 5453 |
| តំបន់វាលទំនាប | 2216 | 20 | 2235 |
| តំបន់បឹងទន្លេសាប | 1891 | 13 | 1904 |
| តំបន់ឆ្នេរសមុទ្រ | 396 | 3 | 400 |
| តំបន់ភ្នំ និងខ្ពង់រាប | 905 | 9 | 914 |

មានកម្មករសរុបជាបុរសដែលជួលមកពីក្រៅចំនួន ៣១.០០០ នាក់ និងស្ត្រីចំនួន ១៣.០០០ នាក់។ ការដាំដំណាំ គឺជាសកម្មភាពទូទៅបំផុតដែលធ្វើឡើងដោយកម្មករមកពីក្រៅ ដោយមានកម្មករចំនួន ៣៩.000 នាក់ (រួមទាំង បុរស និងស្ត្រី) ដែលរាយការណ៍ពីកិច្ចការចម្បងមួយនៃការដាំដំណាំ។

## ជំពូកទី៩ ៖ ព័ត៌មានអំពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ

ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គឺជាអង្គភាពដែលគ្រប់គ្រង និងដំណើរការដោយសហគ្រាសឯកជន ឬរដ្ឋ ដែលរួមទាំង ក្រុមហ៊ុន សាជីវកម្ម ភាពជាដៃគូ សហគមន៍ ស្ថាប័នឯកជន ស្ថាប័នរដ្ឋាភិបាល។ល។ ក្នុងអំឡុងពេលនៃដំណើរការ អង្កេតកសិកម្មឆ្នាំ២០២០ ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំចំនួន ១៩៧ ត្រូវបានរកឃើញថា បានចូលរួមក្នុងសកម្មភាពកសិកម្ម ដែលរួមទាំង ការដាំដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី និងវារីវប្បកម្ម។ ចំនួនកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ត្រូវបានរាយការណ៍ថា មានតិចតួចនៅឡើយ ប៉ុន្តែត្រូវបានកែលម្អ បើប្រៀបធៀបនឹងអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៩។ វិសាលភាពគ្របដណ្តប់នៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ នៅក្នុងអំឡុងពេលអង្កេត ត្រូវបានកំណត់ដោយវិសាលភាពនៃបញ្ជីកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ដែលបានរៀបចំឡើង។ ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋបាលជលផល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានឱ្យដឹងពីការកាន់កាប់សហគ្រាសកកសិកម្មខ្នាតធំដែលបានចុះបញ្ជី និងព័ត៌មានទំនាក់ទំនងលម្អិត។ អ្នកប្រមូលទិន្នន័យបានព្យាយាមទាក់ទងអ្នកកាន់កាប់សហគ្រាសកសិកម្មខ្នាតធំទាំងអស់ ដែល

បានចុះបញ្ជី រួមទាំង ការចុះដល់ទីតាំងនៅតាមខេត្ត និងអាសយដ្ឋានដែលបានចុះឈ្មោះក្នុងរាជធានីភ្នំពេញ។ ក្នុងករណីខ្លះ ការព្យាយាមទាក់ទងអ្នកកាន់កាប់ដែលបានចុះបញ្ជី ពុំទទួលជោគជ័យឡើយ ហើយក្នុងករណីផ្សេងទៀត អ្នកកាន់កាប់ពុំត្រូវបានរកឃើញថា ធ្វើសកម្មភាពកសិកម្មលើដីកាន់កាប់នោះទេ។ កិច្ចប្រឹងប្រែងដែលកំពុងបន្តនឹងធ្វើឡើង ដើម្បីកែលម្អវិសាលភាពគ្របដណ្ដប់នៃបញ្ជីកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ជាមួយវឌ្ឍនភាព និងការពង្រីកដែលបានធ្វើឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

**តារាងទី៩.១. ការប្រើប្រាស់ដីកសិកម្មនៅក្រោមការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ចំនួនកាន់កាប់ដែលរាយការណ៍ កម្រិតតំបន់ ឆ្នាំ២០២០ (១)**

| | ចំនួនកាន់កាប់ | ជាកម្មសិទ្ធិករ/ ជាភោគី | ជួលពីគ្រួសារដទៃ | ប្រើដោយឥតគិតថ្លៃ | សម្បទានដីដែលប្រើប្រាស់ ដោយមានកិច្ចព្រមព្រៀងជាលាយលក្ខអក្សរ | ប្រើប្រាស់ដោយគ្មានការអនុញ្ញាត | កាន់កាប់តាមរូបភាពផ្សេង |
|---|---|---|---|---|---|---|---|
| **កម្រិតថ្នាក់តំបន់/ខេត្ត** | **ចំនួនការកាន់កាប់** | | | | | | |
| **ប្រទេសកម្ពុជា** | 198 | 77 | 7 | 0 | 114 | 0 | 0 |
| **តំបន់វាលទំនាប** | 29 | 19 | 2 | 0 | 8 | 0 | 0 |
| **តំបន់បឹងទន្លេសាប** | 46 | 24 | 3 | 0 | 19 | 0 | 0 |
| **តំបន់ឆ្នេរសមុទ្រ** | 15 | 10 | 0 | 0 | 5 | 0 | 0 |
| **តំបន់ភ្នំ និងខ្ពង់រាប** | 108 | 24 | 2 | 0 | 82 | 0 | 0 |

(១) អ្នកកាន់កាប់ អាចរាយការណ៍ពីជម្រើសឆ្លើយតបច្រើនជាងមួយ។ ដូច្នេះផលបូកនៃចំនួនកាន់កាប់ ដោយជម្រើសឆ្លើយតប អាចលើសពីចំនួនសរុបនៃរបាយការណ៍អំពីការកាន់កាប់។

**តារាងទី៩.២. ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គិតតាមស្ថានភាពចំពោះមុខច្បាប់ នៅកម្រិតតំបន់ ឆ្នាំ២០២០**

| កម្រិតថ្នាក់ជាតិ/តំបន់ | ស្ថានភាពចំពោះមុខច្បាប់នៃការកាន់កាប់ | | | | | | | |
|---|---|---|---|---|---|---|---|---|
| | កម្មសិទ្ធិករតែឯង (គ្មានការចុះបញ្ជី) | កម្មសិទ្ធិករតែឯង (បានចុះបញ្ជី) | ភាពជាដៃគូទូទៅ | ភាពជាដៃគូមានកម្រិតកំណត់ | ក្រុមហ៊ុនឯកជនមានកម្រិតកំណត់ | ក្រុមហ៊ុនសាធារណៈមានកម្រិតកំណត់ | អង្គភាពរដ្ឋ, អង្គភាពស្វយ័ត | ចំនួនកាន់កាប់សរុប |
| | **ចំនួនកាន់កាប់** | | | | | | | |
| **ប្រទេសកម្ពុជា** | 11 | 155 | 2 | 9 | 15 | 1 | 4 | 197 |
| តំបន់វាលទំនាប | 2 | 27 | 0 | 0 | 0 | 0 | 0 | 29 |
| តំបន់បឹងទន្លេសាប | 4 | 29 | 1 | 0 | 11 | 1 | 0 | 46 |
| តំបន់ឆ្នេរសមុទ្រ | 1 | 9 | 0 | 1 | 0 | 0 | 3 | 14 |
| តំបន់ភ្នំ និងខ្ពង់រាប | 4 | 90 | 1 | 8 | 4 | 0 | 1 | 108 |

តារាងទី៩.៣. ការប្រើប្រាស់ដីក្រោមការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ចំនួនកាន់កាប់ដែលបានរាយការណ៍ កម្រិតតំបន់ ឆ្នាំ២០២០

| | កម្រិតថ្នាក់ជាតិ/តំបន់ | | | | |
|---|---|---|---|---|---|
| | ប្រទេសកម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំ និងខ្ពង់រាប |
| ចំនួនកាន់កាប់សរុប | 197 | 29 | 46 | 14 | 108 |
| ជាកម្មសិទ្ធិករ/ជាភោគី | 77 | 19 | 24 | 10 | 24 |
| ជួលពីគ្រួសារផ្សេងទៀតដោយការទូទាត់ជាប្រាក់ និង/ឬផលិតដោយមានកិច្ចព្រមព្រៀងជាលាយលក្ខអក្សរ | 7 | 2 | 3 | 0 | 2 |
| សម្បទានដីប្រើប្រាស់ដោយមានកិច្ចព្រមព្រៀងជាលាយលក្ខអក្សរ (សិទ្ធិប្រើប្រាស់ដែលបានបញ្ជាក់) | 114 | 8 | 19 | 5 | 82 |

តារាងទី៩.៤. ផ្ទៃដីកសិកម្មសរុប គិតតាមចំណាត់ថ្នាក់ទំហំ ចំនួនកាន់កាប់ដែលរាយការណ៍ កម្រិតតំបន់ ឆ្នាំ២០២០

| កម្រិតថ្នាក់ជាតិ/តំបន់ | ការកាន់កាប់ដែលមានដីកសិកម្ម | | | ចំណាត់ថ្នាក់ទំហំសម្រាប់តំបន់កសិកម្ម | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មាន | គ្មាន | សរុប | តូចជាង១ ហ.ត | ១ ដល់ ១៩,៩៩ ហ.ត | ២០ ដល់ ៤៩៩,៩៩ ហ.ត | ៥០០ ដល់ ៩៩៩,៩៩ ហ.ត | ១០០០ ហ.ត និងធំជាង | សរុប |
| **ប្រទេសកម្ពុជា** | 193 | 4 | 197 | 1 | 20 | 61 | 21 | 90 | 193 |
| **តំបន់វាលទំនាប** | 25 | 4 | 29 | 0 | 4 | 14 | 4 | 3 | 25 |
| **តំបន់បឹងទន្លេសាប** | 46 | 0 | 46 | 0 | 10 | 12 | 3 | 21 | 46 |
| **តំបន់ឆ្នេរសមុទ្រ** | 14 | 0 | 14 | 0 | 2 | 4 | 0 | 8 | 14 |
| **តំបន់ភ្នំ និងខ្ពង់រាប** | 108 | 0 | 108 | 1 | 4 | 31 | 14 | 58 | 108 |

តារាងទី៩.៥. ដំណាំ គិតតាមចំនួនកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលបានរាយការណ៍ កម្រិតតំបន់ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

| | កម្រិតថ្នាក់ជាតិ/តំបន់ | | | | |
|---|---|---|---|---|---|
| | ប្រទេសកម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំ និងខ្ពង់រាប |
| ចំនួនកាន់កាប់ដែលរាយការណ៍អំពីដំណាំ | 174 | 20 | 38 | 11 | 105 |
| ស្រូវធម្មតា | 4 | 0 | 1 | 1 | 2 |
| ស្រូវក្រអូប | 2 | 0 | 1 | 0 | 1 |
| ស្រូវដំណើប | 1 | 0 | 1 | 0 | 0 |
| ពោត (ស/លឿង/ស្វាយ) | 3 | 0 | 1 | 1 | 1 |
| ដំឡូងជ្វា | 1 | 0 | 0 | 0 | 1 |
| ដំឡូងមី | 15 | 3 | 4 | 0 | 8 |
| ដំណាំមើម ដំណាំឫស និងដំណាំសរសៃ | 1 | 0 | 0 | 0 | 1 |
| សណ្តែកបាយ | 1 | 0 | 0 | 0 | 1 |
| សណ្តែកសៀង | 3 | 0 | 0 | 0 | 3 |
| ល្ង | 2 | 0 | 0 | 0 | 2 |

| | កម្រិតថ្នាក់ជាតិ/តំបន់ | | | | |
|---|---|---|---|---|---|
| | ប្រទេសកម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំ និងខ្ពង់រាប |
| អំពៅ | 11 | 7 | 0 | 0 | 4 |
| ដំណាំឧស្សាហកម្មផ្សេងទៀត | 6 | 0 | 0 | 3 | 3 |
| បន្លែផ្សេងទៀត | 1 | 0 | 1 | 0 | 0 |
| ក្រូចពោធិសាត់ | 1 | 0 | 0 | 0 | 1 |
| ក្រូចថ្លុង | 1 | 0 | 0 | 0 | 1 |
| ក្រូចឆ្មា | 1 | 0 | 0 | 0 | 1 |
| ចេក | 12 | 2 | 0 | 0 | 10 |
| មៀន | 1 | 0 | 0 | 0 | 1 |
| ស្វាយ | 25 | 2 | 6 | 1 | 16 |
| ម្នាស់ | 1 | 0 | 0 | 0 | 1 |
| ខ្នុរ | 5 | 0 | 0 | 0 | 5 |
| សាវម៉ាវ | 1 | 0 | 0 | 1 | 0 |
| ទុរេន | 8 | 0 | 1 | 2 | 5 |
| ផ្លែស្រកានាគ | 2 | 0 | 0 | 0 | 2 |
| ផ្លែប៉ាស្សុង | 1 | 0 | 0 | 0 | 1 |
| ផ្លែល្មើ | 3 | 1 | 1 | 0 | 1 |
| ស្វាយចន្ទី | 40 | 5 | 10 | 1 | 24 |
| ដូង | 6 | 1 | 1 | 1 | 3 |
| ដូងប្រេង | 4 | 0 | 0 | 2 | 2 |
| ម្រេច | 8 | 1 | 1 | 0 | 6 |
| ដំណាំគ្រឿងទេស និងក្រអូបផ្សេងទៀត | 1 | 0 | 0 | 0 | 1 |
| កៅស៊ូ | 108 | 9 | 26 | 3 | 70 |
| ដើមប្រេងខ្យល់ | 3 | 0 | 0 | 0 | 3 |
| ដើមឈើ | 1 | 0 | 0 | 0 | 1 |
| ដំណាំអចិន្ត្រៃយ៍មិនមែនអាហារ | 2 | 1 | 0 | 0 | 1 |
| ដំណាំផ្សេងទៀតគ្មានក្នុងចំណាត់ថ្នាក់ | 2 | 0 | 0 | 2 | 0 |

**តារាងទី៩.៦. ដំណាំ - ការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលបានរាយការណ៍ ផ្ទៃដីដាំ ផ្ទៃដីប្រមូលផល បរិមាណផល ទិន្នផល កម្រិតតំបន់ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ - ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០**

| កម្រិតថ្នាក់ជាតិ/តំបន់ | ចំនួនកាន់កាប់សរុបដែលរាយការណ៍អំពីដំណាំ | ការកាន់កាប់ដែលរាយការណ៍ពីដំណាំលាយចម្រុះជាមួយដំណាំផ្សេងទៀត | ផ្ទៃដីដាំ | ផ្ទៃដីប្រមូលផល | បរិមាណផល | ទិន្នផល | ចំនួនកាន់កាប់ដែលរាយការណ៍ពីដំណាំដែលបានលក់ | ភាគរយដំណាំដែលបានលក់ | បរិមាណដែលបានលក់ | ឯកត្តាថ្លៃក្នុងមួយគីឡូក្រាម |
|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកាន់កាប់ | | ហិកតា | | តោន | គ.ក្រ/ហ.ត | ចំនួនកាន់កាប់ | ភាគរយ | តោន | រៀល |
| ស្រូវធម្មតា | 4 | 1 | 563 | 563 | 1.130 | 1.310 | 4 | 80% | 1.110 | 855 |
| ស្រូវក្រអូប | 2 | 0 | 61 | 61 | 181 | 1.887 | 1 | 50% | 180 | 900 |
| ស្រូបដំណើប | 1 | 0 | 0 | 0 | 0 | 694 | 0 | - | - | - |
| ពោត(ស/លឿង/ស្វាយ) | 3 | 1 | 938 | 932 | 5.773 | 2.589 | 3 | 100% | 5.773 | 643 |
| ដំឡូងជ្វា | 1 | 0 | 20 | 0 | 0 | | 0 | - | - | - |
| ដំឡូងមី | 15 | 4 | 15.115 | 12.494 | 80.446 | 10.132 | 10 | 100% | 80.446 | 286 |
| សណ្តែកបាយ | 1 | 0 | 56 | 56 | 65 | 1.161 | 1 | 100% | 65 | 4.000 |
| សណ្តែកសៀង | 3 | 1 | 645 | 645 | 784 | 1.085 | 3 | 98% | 774 | 1.700 |
| ល្ង | 2 | 0 | 280 | 280 | 121 | 550 | 2 | 98% | 120 | 7.000 |
| អំពៅ | 11 | 0 | 8.850 | 3.081 | 98.344 | 28.509 | 7 | 99% | 97.203 | 1.130 |
| ក្រូចពោធិសាត់ | 1 | 0 | 3 | 3 | 45 | 15.000 | 1 | 99% | 44 | 4.000 |
| ចេក | 12 | 3 | 16.947 | 12.274 | 342.333 | 21.324 | 7 | 88% | 342.327 | 1.532 |
| ស្វាយ | 25 | 6 | 8,280 | 1.752 | 17.247 | 6.217 | 10 | 91% | 17.242 | 1.240 |
| ម្នាស់ | 1 | 1 | 339 | 0 | 0 | | 0 | - | - | - |
| ខ្នុរ | 5 | 2 | 911 | 76 | 761 | 10.013 | 1 | 100% | 761 | 2.600 |
| ទុរេន | 8 | 3 | 710 | 0 | 0 | 10.000 | 1 | 100% | 0 | 20.000 |
| ស្វាយចន្ទី | 40 | 8 | 20.586 | 4.600 | 2.333 | 573 | 20 | 95% | 1.970 | 3.870 |
| ដូង | 6 | 0 | 446 | 0 | 0 | | 0 | - | - | - |
| ម្រេច | 8 | 3 | 217 | 81 | 82 | 1.146 | 7 | 95% | 74 | 8.643 |
| កៅស៊ូ | 108 | 11 | 170.141 | 88.780 | 511.339 | 7.261 | 67 | 98% | 510.961 | 3.094 |

## តារាងទី៩.៧. ចំនួនកាន់កាប់ដែលផ្តោតលើការចិញ្ចឹមបសុសត្វ គិតតាមសកម្មភាពបសុសត្វសំខាន់ៗ កម្រិតតំបន់ ឆ្នាំ២០២០

| កម្រិតថ្នាក់ជាតិ/តំបន់ | ចំនួនកាន់កាប់សរុប | ចិញ្ចឹមបសុសត្វធំៗ | ចិញ្ចឹមបសុសត្វតូចៗ | ចិញ្ចឹមបសុបក្សី | ចំនួនកាន់កាប់សរុបដែលចិញ្ចឹមបសុសត្វ/បសុបក្សី/សត្វល្អិត |
|---|---|---|---|---|---|
| | ចំនួនកាន់កាប់ | | | | |
| ប្រទេសកម្ពុជា | 197 | 8 | 19 | 7 | 32 |
| តំបន់វាលទំនាប | 29 | 3 | 3 | 2 | 7 |
| តំបន់បឹងទន្លេសាប | 46 | 4 | 5 | 3 | 12 |
| តំបន់ឆ្នេរសមុទ្រ | 14 | 1 | 3 | 0 | 4 |
| តំបន់ភ្នំ និងខ្ពង់រាប | 108 | 0 | 8 | 2 | 9 |

## តារាង ៩.៨. បសុសត្វ និងបសុបក្សី ចំនួនកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលរាយការណ៍ ចំនួនសត្វដែលបានរាយការណ៍ និងចំនួនសត្វជាមធ្យមដែលរាយការណ៍នៅក្រោមការកាន់កាប់នីមួយៗ ចំនួនកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលរាយការណ៍អំពីសត្វឃាដ

| កម្ពុជា | | | | | |
|---|---|---|---|---|---|
| | ចំនួនកាន់កាប់ដែលរាយការណ៍អំពីវត្តមានសត្វក្នុងអំឡុងពេល ១២ខែចុងក្រោយ | ចំនួនកាន់កាប់ដែលរាយការណ៍អំពីវត្តមានសត្វនៅថ្ងៃយោង | ចំនួនសត្វសរុបក្នុងការកាន់កាប់ នៅថ្ងៃយោង | ចំនួនសត្វជាមធ្យមក្នុងមួយកសិដ្ឋានដែលរាយការណ៍ (ចំនួនសត្វ/ចំនួនកាន់កាប់ដែលរាយការណ៍អំពីវត្តមានសត្វនៅថ្ងៃយោង | ចំនួនកាន់កាប់ដែលរាយការណ៍អំពី សត្វឃាដ |
| គោ | | | | | |
| គោ ទាំងអស់ | 7 | 7 | 1128 | 161,14 | 0 |
| គោ លក់រស់ | 6 | 6 | 968 | 161,33 | 0 |
| គោ គោផ្សេងទៀត | 1 | 1 | 160 | 160 | 0 |
| ក្របី | | | | | |
| ក្របី ទាំងអស់ | 1 | 1 | 42 | 42 | 0 |
| ក្របី លក់រស់ | 1 | 1 | 42 | 42 | 0 |
| ជ្រូក | | | | | |
| ជ្រូក ទាំងអស់ | 19 | 19 | 237.658 | 12.508 | 4 |
| ជ្រូក លក់រស់ | 19 | 19 | 237.658 | 12.508 | 4 |
| បសុបក្សី | | | | | |
| បសុបក្សី ទាំងអស់ | 7 | 7 | 328.050 | 46.864 | 3 |
| បសុបក្សី មាន់ | 6 | 6 | 326.050 | 54.342 | 2 |
| បសុបក្សី ទា | 1 | 1 | 2.000 | 2.000 | 1 |

តារាងទី ៩.៩. ប្រភេទវារីវប្បកម្ម ចំនួនកាន់កាប់សហគ្រាសកសិកម្មខ្នាតធំដែលរាយការណ៍ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩ - ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

| កម្រិតថ្នាក់ជាតិ/តំបន់ | វារីវប្បកម្ម | | | | | ការធ្វើនេសាទ | | |
|---|---|---|---|---|---|---|---|---|
| | ចំនួនកាន់កាប់ដែលរាយការណ៍អំពីសកម្មភាពវារីវប្បកម្ម | ស្រះ | | | | ចំនួនកាន់កាប់ដែលរាយការណ៍អំពីសកម្មភាពនេសាទ | ទឹកសាប | ចំនួនកាន់កាប់ដែលរាយការណ៍អំពីវារីវប្បកម្ម និងសកម្មភាពនេសាទ |
| | | ចំនួនកាន់កាប់ | ចំនួនដងជាមធ្យមដែលស្រះ ឬស្រូវបានលិចលង់ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ | | | | ចំនួនកាន់កាប់ | |
| | | | 0 លើក | ១-៥ លើក | ៦-១០លើក | | | |
| ប្រទេសកម្ពុជា | 8 | 8 | 7 | 1 | 0 | 1 | 1 | 1 |
| តំបន់វាលទំនាប | 5 | 5 | 4 | 1 | 0 | 1 | 1 | 1 |
| តំបន់បឹងទន្លេសាប | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| តំបន់ឆ្នេរសមុទ្រ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| តំបន់ភ្នំ និងខ្ពង់រាប | 3 | 3 | 3 | 0 | 0 | 0 | 0 | 0 |

តារាងទី៩.១០. ប្រភេទពូជក្នុងការចិញ្ចឹម ចំនួនកាន់កាប់ដែលរាយការណ៍ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩ ដល់ ថ្ងៃទី ៣០ ខែមិថុនា ២០២០

| | ប្រទេសកម្ពុជា | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួនកាន់កាប់ដែលរាយការណ៍អំពីប្រភេទ | តួលេខបច្ចុប្បន្នគិតត្រឹមថ្ងៃសម្ភាស | ប្រភេទប្រមូលផលក្នុងអំឡុងពេលយោង | ការកាន់កាប់ដែលរាយការណ៍ពីប្រភេទចំបងៗនៃចំណីដែលបានប្រើប្រាស់ | | | | | ការកាន់កាប់ដែលរាយការណ៍ពីការលក់ | | % នៃប្រភេទដែលបានលក់ | ឯកត្តាថ្លៃក្នុងពេលលក់ចុងក្រោយ |
| | | | | ចំណីគ្រាប់ | ត្រីដី | ធ្វើខ្លួនឯង | មិនផ្តល់ចំណី | ផ្សេងទៀត | | | | |
| *ប្រភេទត្រីក្នុងការចិញ្ចឹម* | ចំនួនកាន់កាប់ | ចំនួនត្រី | គ.ក្រ | ចំនួនកាន់កាប់ | | | | | | ជា% នៃការកាន់កាប់ទាំងអស់ដែលរាយការណ៍អំពីប្រភេទ | | រៀល/គ.ក្រ |
| ទីឡាព្យា | 3 | 140.000 | 5.035 | 2 | 0 | 0 | 1 | 1 | 3 | 100 | 100 | 7.833 |
| ត្រីឆ្ពិន | 1 | 20.000 | 2.000 | 0 | 0 | 1 | 0 | 0 | 1 | 100 | 100 | 10.000 |
| ត្រីប្រាធំ | 6 | 427.100 | 101.251 | 3 | 0 | 3 | 0 | 0 | 3 | 50 | 100 | 6.533 |
| ត្រីអណ្តែង | 1 | 12.500 | 3.125 | 1 | 0 | 0 | 0 | 0 | 1 | 100 | 100 | 8.000 |

| | ប្រទេសកម្ពុជា | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួនកាន់កាប់សរុបដែល រាយការណ៍អំពីសកម្មភាពនេសាទ | ចំនួនកាន់កាប់ដែលរាយការណ៍អំពីប្រភេទត្រី | ភាគរយសរុបនៃការកាន់កាប់ដែលរាយការណ៍អំពីប្រភេទត្រី | ផលចាប់សរុបក្នុងអំឡុងពេលយោង | ចំនួនកាន់កាប់ដែលរាយការណ៍ធៀបនឹងផលចាប់ឆ្នាំមុន | ប្រភពផលចាប់ពី | % ផលចាប់ប្រើសម្រាប់ | ឯកត្តាថ្លៃលក់លើកចុងក្រោយ (ប្រភេទ) |
| | | | | | ស្រដៀងឆ្នាំមុន | ទឹកសាប | លក់ | |
| *ប្រភេទ* | ចំនួន | ចំនួន | ភាគរយ | គ.ក្រ | ចំនួនកាន់កាប់ | ចំនួនកាន់កាប់ | ភាគរយ | រៀល/គ.ក្រ |
| ត្រី | 1 | 1 | 100,00% | 20 | 1 | 1 | 100 | 4.000 |

តារាងទី៩.១១. សកម្មភាពផ្សេងទៀតនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ គិតតាមចំនួនកាន់កាប់ដែលរាយការណ៍ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២០

| កម្រិតថ្នាក់ជាតិ/តំបន់ | | ចំនួនកាន់កាប់សរុប | | សកម្មភាពផ្សេងទៀតនៃការកាន់កាប់ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
